**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ការរៀបចំក្រុងច្បារមន (ខេត្តកំពង់ស្ពឺ) ឱ្យមានសណ្ដាប់ធ្នាប់ និងសោភ័ណភាព

ស្រាវជ្រាវ ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

ស្រាវជ្រាវដោយ៖ | សាស្ត្រាចារ្យណែនាំ

និស្សិតឈ្មោះ លោក **ជា ប៉េងឡុង** | បណ្ឌិត **អ៊ុំន សកក្ដដា**

កញ្ញា **ប៉ោ សៀងហ៊ុយ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០១៤

ជំនាន់ទី១៨ | ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ជា ម៉េងឡុង** និងនាងខ្ញុំឈ្មោះ **ប៉ោ សៀងហ៊ុយ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ក្រុម **L4A3** ជំនាន់ទី១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា ២០១៧-២០១៨។

**សូមសម្តែងនូវការដឹងគុណដ៏ខ្ពង់ខ្ពស់ជាអនេកប្បការជូនចំពោះ**

- **លោកឪពុក និង អ្នកម្តាយ** ដែលបានផ្តល់កំណើត និងបានខិតខំពុះពារគ្រប់ឧបសគ្គក្នុងការចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅ និងបានផ្គត់ផ្គង់កូនគ្រប់សព្វបែបយ៉ាងទាំងសម្ភារសម្រាប់ប្រើប្រាស់រៀនសូត្រ និងស្មារតីដល់កូន ជាពិសេសលោកទាំងទ្វេបានខិតខំជំរុញឱ្យកូនបានសិក្សារៀនសូត្ររហូតមកដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។ គុណូបការៈដែលលោកទាំងទ្វេបានផ្តល់ និងលះបង់នេះ វាជាវត្ថុដ៏មានតម្លៃបំផុតដែលមិនអាចកាត់ថ្លៃបាន និងមិនអាចរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ ហើយគ្មានថ្ងៃណាដែលកូនបានតបស្នងសងគុណលោកវិញអស់ឡើយ។
- **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្រ្តាចារ្យ និងបុគ្គលិក** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ ដែលបានជួយតម្រង់ទិសក្នុងការសិក្សារៀនសូត្ររហូតទទួលបានជោគជ័យ និងឈានដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។
- **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងមន្រ្តីរាជការដែលកំពុងបម្រើការងារក្នុងរដ្ឋបាលខេត្តកំពង់ស្ពឺ** ដែលបានជួយសម្របសម្រួលក្នុងការចុះស្រាវជ្រាវ ប្រមូលឯកសារ និងទិន្នន័យនានាដែលពាក់ព័ន្ធនឹងប្រធានបទសារណាខាងលើនេះ។
- ជាពិសេស **លោកសាស្រ្តាចារ្យ បណ្ឌិត អ៊ុន សកក្កដា** ដែលបានដឹកនាំ ចង្អុលបង្ហាញ សម្របសម្រួល ផ្តល់ដំបូន្មាន និងអនុសាសន៍ល្អៗ ព្រមទាំងពន្យល់ពីវិធីសាស្រ្តក្នុងការស្រាវជ្រាវឯកសារ និងទិន្នន័យនានាដែលពាក់ព័ន្ធនឹងប្រធានបទសារណាមួយនេះ រួមទាំងការចំណាយពេលដ៏មានតម្លៃក្នុងការដឹកនាំសរសេរសារណាមួយនេះតាំងពីដើមរហូតដល់ចប់។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់សុំបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមជួយតាមថែរក្សាលោកទាំងអស់ឱ្យជួបប្រទះតែសេចក្តីសុខ សុខភាពល្អ អាយុយឺនយូរ ដើម្បីបន្តដឹកនាំ និងផ្តល់ចំណេះដឹងដល់កុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយៗទៀត។

## អារម្ភកថា

"ការរៀបចំក្រុងច្បារមន (ខេត្តកំពង់ស្ពឺ) ឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាព" គឺជាប្រធានបទមួយដែលគួរឱ្យចាប់អារម្មណ៍ និងមានសារៈសំខាន់ជាទីបំផុត។ វាជាស្នាដៃមួយដែលបានកើតចេញពីការខិតខំប្រឹងប្រែងសិក្សារៀនសូត្រ ស្រាវជ្រាវ និងសហការគ្នាប្រកបដោយឆន្ទៈដ៏មុះមុតជាធ្លុងមួយ តាមរយៈការខិតខំស្វះស្វែងរិះរកឯកសារពាក់ព័ន្ធ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីធ្វើការផ្លាស់ប្តូរមតិយោបល់ និងគោលគំនិតពីគ្នាទៅវិញទៅមក ដែលវាជាចំណុចស្នូលមួយឈានទៅរកការសរសេរបញ្ចប់សារណាមួយនេះឡើង។

យើងខ្ញុំទាំងពីរនាក់សង្ឃឹមថាសារណាមួយនេះនឹងមានគុណប្រយោជន៍ចំពោះមិត្តនិស្សិត មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទាំងអស់ឱ្យយល់ដឹងកាន់តែច្បាស់អំពីការអភិវឌ្ឍនានានៅក្នុងក្រុងច្បារមន និងយុទ្ធសាស្ត្រនៃការរៀបចំក្រុងច្បារមនឱ្យប្រែក្លាយជាក្រុងមួយដែលមានសណ្តាប់ធ្នាប់ និងសោភ័ណភាព។

ទោះបីជាយើងខ្ញុំទាំងពីរនាក់បានខិតខំរៀបចំ និងត្រួតពិនិត្យសារណាមួយនេះយ៉ាងណាក្តីក៏នៅមានចំណុចខ្វះខាតមួយចំនួនដែលអាចកើតមានឡើងខានពុំបាន ដូច្នេះយើងខ្ញុំក៏សូមមេត្តាខន្តីអភ័យទោសចំពោះមិត្តនិស្សិត មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទាំងអស់ចំពោះសារណាមួយនេះ បើសិនជាមានចំណុចខ្វះខាត ខ្វះចន្លោះ នៅត្រង់ចំណុចណាមួយទោះបីជាកំហុសនោះកើតឡើងដោយចេតនាក្តី ឬ អចេតនាក្តី យើងខ្ញុំនឹងរង់ចាំទទួលយកនូវមតិរិះគន់កែតម្រូវព្រមទាំងទទួលយកអនុសាសន៍ល្អៗគ្រប់ពេលវេលាក្នុងន័យ ដើម្បីកែលម្អសារណាមួយនេះឱ្យកាន់តែល្អប្រសើរឡើងបន្ថែមទៀត។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ........ ១

## ជំពូកទី១
## សញ្ញាណនៃការរៀបចំក្រុង

**១.១.មូលហេតុដែលនាំឱ្យមានការរៀបចំក្រុង** ........ ៣
**១.១.១.កំណើនប្រជាជន និងភាពក្រីក្រ** ........ ៣
១.១.១.១.កំណើនប្រជាជន ........ ៣
១.១.១.២.ភាពក្រីក្រ ........ ៣
**១.១.២.កម្រិតជីវភាពរស់នៅ និងការដាក់សម្ពាធបរិស្ថាន** ........ ៤
១.១.២.១.កម្រិតជីវភាពរស់នៅ ........ ៤
១.១.២.២.ការដាក់សម្ពាធបរិស្ថាន ........ ៥
**១.២.ស្ថានភាពទូទៅនៃក្រុងច្បារមន** ........ ៥
**១.២.១.ទីតាំងភូមិសាស្ត្រ និងតំបន់ទាក់ទាញ** ........ ៥
១.២.១.១.ទីតាំងភូមិសាស្ត្រ ........ ៥
១.២.១.២.តំបន់ទាក់ទាញ ........ ៦
**១.២.២.រដ្ឋបាលក្រុង** ........ ៧
១.២.២.១.រដ្ឋបាលដែនដី ........ ៧
១.២.២.២.តួនាទី ភារកិច្ចក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុង ........ ៨

## ជំពូកទី២
## ការរៀបចំក្រុងច្បារមនឱ្យមានសោភ័ណភាព និងសណ្ដាប់ធ្នាប់

**២.១.ការរៀបចំក្រុងច្បារមន** ........ ១៩
**២.១.១.សោភ័ណភាព** ........ ១៩
២.១.១.១.ពេលថ្ងៃ ........ ១៩
២.១.១.២.ពេលយប់ ........ ២២
**២.១.២.សណ្ដាប់ធ្នាប់** ........ ២៣
២.១.២.១.សន្តិសុខ ........ ២៣
២.១.២.២.ភាពស្ងប់ស្ងៀម ........ ២៥

២.១.២.៣.អនាម័យ ...................................................................................២៦
**២.២.បញ្ហាក្នុងការអភិវឌ្ឍក្រុង** .............................................................................. ៣១
២.២.១.បញ្ហាប្រឈម ............................................................................................ ៣១
២.២.២.ដំណោះស្រាយ.............................................................................................៣២
**សេចក្តីសន្និដ្ឋាន**................................................................................................ ៣៥
**អនុសាសន៍**........................................................................................................ ៣៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

បន្ទាប់ពីប្រទេសកម្ពុជាបានរំដោះចេញពីរបបខ្មៅងងឹត ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ (របបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីឆ្នាំ១៩៧៥-១៩៧៩) ព្រមទាំងមានការចរចាបង្រួបបង្រួមគ្នាឡើងវិញរវាងខ្មែរនិងខ្មែរ នាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩១ រហូតឈានដល់មានការបោះឆ្នោតសារឡើងវិញដែលបានរៀបចំឡើងដោយអង្គការសហប្រជាជាតិនាឆ្នាំ១៩៩៣រួចមក ប្រទេសកម្ពុជាបានរៀបចំកសាងប្រទេសឡើងវិញចាប់តាំងពីបាតដៃទទេរហូតដល់មានការអភិវឌ្ឍដូចសព្វថ្ងៃនេះ។ តួយ៉ាងការចាប់ផ្តើមរៀបចំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឡើងវិញវាពិតជាមានផលលំបាកយ៉ាងខ្លាំងហើយក្រុងច្បារមនក៏មិនខុសពីក្រុងដទៃទៀតដែរនៅក្នុងប្រទេសកម្ពុជា ក្រុងនេះពីមុនឡើយជាក្រុងមួយដែលពុំសូវមានប្រជាជនបានស្គាល់ឡើយ ជាពិសេសគឺភ្ញៀវទេសចរដែលបានធ្វើដំណើរឆ្លងកាត់ទីនោះ ព្រោះថាក្រុងនេះមានភាពស្ងប់ស្ងាត់ពុំសូវមានអ្វីដែលអភិវឌ្ឍគួរឱ្យកត់សម្គាល់នោះទេ ប៉ុន្តែក្នុងរយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះ យើងសង្កេតឃើញថាក្រុងមួយនេះបានប្រែក្លាយពីក្រុងដែលមានភាពស្ងប់ស្ងាត់ឱ្យទៅជាក្រុងមួយដែលមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់យ៉ាងខ្លាំង ដូចជាសួនច្បារតាមបណ្តោយស្ទឹងព្រែកត្នោត វិមានតម្កល់រូបសំណាកសម្តេចព្រះសង្ឃរាជជួនណាតជោតញ្ញាណោ វិមានឯករាជ្យ ផ្សាររាត្រី កន្លែងហាត់ប្រាណ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធដទៃទៀតដែលត្រូវបានរៀបចំកែលម្អដោយមានការតុបតែងភ្លើងពណ៌នាពេលរាត្រី អមទៅដោយការបាញ់ទឹកនៅកណ្តាលស្ទឹង និងសួនច្បារយ៉ាងស្អាត ដែលបានទាក់ទាញប្រជាពលរដ្ឋដែលរស់នៅទីនោះ ក៏ដូចជាភ្ញៀវទេសចរឱ្យចូលមកទស្សនា និងលេងកម្សាន្ត។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទខាងលើត្រូវធ្វើឡើងដោយឆ្លើយតបនឹងសំណួរដូចខាងក្រោម៖

១.ហេតុអ្វីបានជាចាំបាច់ត្រូវរៀបចំក្រុងច្បារមន?

២.តើគួរធ្វើយ៉ាងដូចម្តេច ដើម្បីរៀបចំក្រុងច្បារមនឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាព?

៣.តើអាជ្ញាធរពាក់ព័ន្ធមានវិធានការយ៉ាងដូចម្តេច ក្នុងការដោះស្រាយបញ្ហាដែលបានកើតមានឡើងក្នុងការអភិវឌ្ឍក្រុង?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រធានបទខាងលើនេះ មានគោលបំណងចង់ឱ្យមិត្តនិស្សិត មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទាំងអស់ឱ្យបានស្វែងយល់ពីផែនការយុទ្ធសាស្ត្រនានារបស់

អាជ្ញាធរពាក់ព័ន្ធក្នុងក្រុងច្បារមន ដើម្បីធ្វើយ៉ាងណារៀបចំក្រុងមួយនេះឱ្យមានសណ្តាប់ធ្នាប់ និង សោភ័ណភាព ព្រមទាំងបង្ហាញពីសមិទ្ធផលនានាដែលមាននៅក្នុងក្រុងនាពេលបច្ចុប្បន្នផងដែរ។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទាំងឡាយគឺតែងតែមានដែនកំណត់របស់ខ្លួន។ ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទដែលទាក់ទងនឹង "**ការរៀបចំក្រុងច្បារមន (ខេត្តកំពង់ស្ពឺ) ឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាព**" គឺយើងសិក្សាស្រាវជ្រាវទៅលើឯកសារ និងលិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងនឹងសណ្តាប់ធ្នាប់ និងសោភ័ណភាពតែប៉ុណ្ណោះ។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះពិតជាបានចូលរួមចំណែកមួយយ៉ាងសំខាន់ ជាពិសេសបានផ្តល់នូវពុទ្ធិដល់មិត្តនិស្សិត មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនទាំងអស់ឱ្យយល់ដឹងកាន់តែស៊ីជម្រៅអំពីការរៀបចំផែនការយុទ្ធសាស្ត្រក្នុងការអភិវឌ្ឍនៅក្នុងក្រុង ដើម្បីធ្វើយ៉ាងណាឱ្យរៀបចំក្រុងច្បារមនឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាព ព្រមទាំងប្រែក្លាយក្រុងមួយនេះឱ្យកាន់តែមានភាពរីកចម្រើនបន្ថែមទៀតនាពេលអនាគត។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ "**ការរៀបចំក្រុងច្បារមន (ខេត្តកំពង់ស្ពឺ) ឱ្យមានសណ្តាប់ធ្នាប់ និងសោភ័ណភាព**" គឺក្រុមខ្ញុំបានធ្វើការស្វែងរកឯកសារពាក់ព័ន្ធនានា នៅក្នុងបណ្ណាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ស្ថាប័ន អង្គភាពនានាក្នុងរដ្ឋបាលខេត្តកំពង់ស្ពឺ និងតាមរយៈអ៊ីនធឺណែត ដោយក្នុងនោះយើងខ្ញុំបានប្រមូលផ្តុំឯកសារទាំងនោះបន្ទាប់មកសិក្សា និងវិភាគ ព្រមទាំងចុះស្វែងរកទិន្នន័យជាក់ស្តែងនៅតាមបណ្តាស្ថាប័ន អង្គភាពពាក់ព័ន្ធក្នុងក្រុងច្បារមនផងដែរ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះត្រូវបានបែងចែកជា ២ ជំពូកគឺ៖

- **ជំពូកទី១ "សញ្ញាណនៃការរៀបចំក្រុង"** ៖ ក្នុងជំពូកនេះនិយាយអំពីបុព្វហេតុដែលនាំឱ្យមានការរៀបចំក្រុង និងស្ថានភាពទូទៅនៃក្រុងច្បារមន។
- **ជំពូកទី២ "ការរៀបចំក្រុងច្បារមនឱ្យមានសោភ័ណភាព និងសណ្តាប់ធ្នាប់"** ៖ ក្នុងជំពូកនេះនិយាយអំពីការរៀបចំក្រុងច្បារមន និងបញ្ហាក្នុងការអភិវឌ្ឍក្រុង។

# ជំពូកទី១

# សញ្ញាណនៃការរៀបចំក្រុង

# ជំពូកទី១
# សញ្ញាណនៃការរៀបចំក្រុង

## ១.១.មូលហេតុដែលនាំឱ្យមានការរៀបចំក្រុង

ជាការពិតណាស់ការរៀបចំមួយចាំបាច់ត្រូវធ្វើឡើង ដោយត្រូវគិតគូរឱ្យបានហ្មត់ចត់សព្វគ្រប់ជ្រុងជ្រោយ ហើយការរៀបចំនេះពុំមែនជាភាពចៃដន្យនោះទេ ពោលគឺមានកត្តាជាច្រើនដែលជួយជំរុញឱ្យមានការរៀបចំក្រុង កត្តាទាំងនោះមានខាងក្រោម៖

### ១.១.១.កំណើនប្រជាជន និងភាពក្រីក្រ

#### ១.១.១.១.កំណើនប្រជាជន

ជាទូទៅ មាននូវសមាសភាពនៃកំណើនប្រជាជនក្នុងទីក្រុង ៣ សំខាន់ៗ គឺ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ កំណើនដោយសារមានចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មី ដែលពីមុនមកតំបន់នេះជាទីជនបទប៉ុណ្ណោះ។ កំណើនប្រជាជនក្នុងក្រុងជាលក្ខណៈធម្មជាតិ ធ្វើឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនៃចំនួនប្រជាជន ចំណែកឯកំណើនដោយសារមានចំណាកស្រុកពីជនបទ និងកំណើនដោយសារតែការបែងចែកប្រភេទសណ្ឋាននៃក្រុងថ្មីដែលពីមុនមកតំបន់នេះជាទីជនបទ គ្រាន់តែជាធាតុបន្ទាប់បន្សំតែប៉ុណ្ណោះ។[១]

#### ១.១.១.២.ភាពក្រីក្រ

ការកំណត់អំពីស្ថានភាពក្រីក្រមានការលំបាកនៅក្នុងការកំណត់ណាស់ តែជាទូទៅភាពក្រីក្រសំដៅដល់ការដែលតម្រូវការរបស់មនុស្សមិនត្រូវបានបំពេញ។ ជារួមប្រទេសភាគច្រើនបានកំណត់ពីភាពក្រីក្រតាមរយៈប្រាក់ចំណូលទាប ដែលពួកគេមិនអាចចាយវាយគ្រប់គ្រាន់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃឡើយ។ តម្រូវការរូបកាយ ចំណីអាហារ លំនៅដ្ឋាន ការងារ ធនធានទឹក អគ្គិសនី អនាម័យ សុខុមាលភាពសង្គម មានការខ្វះខាត។ លើសពីនេះសិទ្ធិសេរីភាពផ្នែកស្មារតីនិយាយជារួម និងនិយាយដោយឡែកសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏នៅមានកម្រិតដែរ។

ការសម្គាល់ពីភាពក្រីក្រត្រូវបានសង្កត់ធ្ងន់លើចំណូលទាបរបស់បុគ្គលមួយរូបៗ ពីព្រោះតែបញ្ហាផ្សេងៗដូចជា ចំនួននៃករណីឧក្រិដ្ឋកម្ម អំពើហិង្សា ឬ អាយុសង្ឃឹមរស់ជាមធ្យមមិនអាចយកមកជំនួសដោយការវាស់ស្ទង់តាមរយៈប្រាក់ចំណូលនេះឡើយ ដែលជាធម្មតាអ្នកដែលទទួលបានប្រាក់ចំណូលក្រោមកម្រិតមធ្យមត្រូវបានគេសន្មត់ថាជាជនក្រីក្រ។ យ៉ាងហោចណាស់ជាង ២០%

[១] បណ្ឌិត អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (២០១៨), ៦។

នៃចំនួនប្រជាជនពិភពលោករស់នៅក្នុងបន្ទាត់នៃភាពក្រីក្រ ហើយ ៩០% ក្នុងចំនួននេះកំពុងស្ថិតនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។

- **ភាពក្រីក្រនៅតាមជនបទ** ៖ ស្ថិតក្នុងបរិការណ៍នៃបច្ចុប្បន្នភាព ស្ថានភាពក្រីក្រនៃប្រទេសកំពុងអភិវឌ្ឍមានការកើនឡើងជាលំដាប់។ កំណើននេះអាស្រ័យដោយស្ថានភាពសេដ្ឋកិច្ចសង្គម ប្រជាសាស្ត្រ ភូមិសាស្ត្រ នយោបាយ គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងកង្វះដីបង្កបង្កើនផលជាដើម។ ភាពក្រីក្រនៅជនបទនាំឱ្យមានចំណាកស្រុកទៅទីក្រុង ហើយចរន្តការនេះនឹងកើនឡើងនៅពេលដែលស្ថានភាពនៅតំបន់ជនបទកាន់តែលំបាក។ ដូច្នេះ ការបង្កើនសកម្មភាពសេដ្ឋកិច្ចនៅជនបទជាវិធីសាស្ត្រមួយដ៏មានប្រសិទ្ធភាពជាទីបំផុត ដើម្បីគ្រប់គ្រងការធ្វើចំណាកស្រុកនេះ។

- **ភាពក្រីក្រនៅទីក្រុង** ៖ ជាទូទៅ ពុំមាននូវលក្ខណៈសមភាពទេ កាលណាគេធ្វើការប្រៀបធៀបពីភាពក្រីក្រដោយដាក់បន្ទាត់មួយក្រិតឱ្យស្មើគ្នានោះ។ ឧទាហរណ៍ ការប្រើប្រាស់ថវិកា ១ ដុល្លារសហរដ្ឋអាមេរិក ដូចគ្នា តែបុគ្គលម្នាក់នៅជនបទ ចំណែកបុគ្គលម្នាក់ទៀតនៅទីក្រុងមិនស្មើគ្នាទេ។ មូលហេតុនោះគឺដោយសារថាជាធម្មតាការចំណាយនៅក្នុងទីក្រុងខ្ពស់ជាងជនបទដាច់ស្រយាលឆ្ងាយណាស់។ ស្របពេលជាមួយគ្នានេះ អ្នករស់នៅតាមទីជនបទអាចមានឱកាសស្វែងរកការចិញ្ចឹមជីវិត តាមរយៈការទទួលអំណោយភោគផលពីធម្មជាតិច្រើនជាងអ្នកនៅទីក្រុង។ តាមរយៈនេះគេអាចនិយាយបានថា អ្នកក្រនៅទីក្រុង ក្រជាង និងមានស្ថានភាពលំបាកជាងអ្នកក្រនៅជនបទ។ ដោយឡែកការនិយាយបែបនេះក៏ពុំត្រឹមត្រូវទាំងស្រុងនោះដែរ ដោយហេតុថាអ្នករស់នៅទីក្រុងមានបរិយាកាសសង្គមដែលបង្កលក្ខណៈវិជ្ជមានច្រើនដល់ឱកាសការងារ ការសិក្សា អប់រំ សុខាភិបាល សុខុមាលភាពសង្គម អនាម័យសាធារណៈ ដែលអាចជួយឱ្យអ្នកដែលស្ថិតនៅក្នុងភាពក្រីក្រ អាចមានឱកាសដើរចេញពីស្ថានភាពលំបាកនេះក្នុងកម្រិតខ្ពស់។[២]

## ១.១.២.កម្រិតជីវភាពរស់នៅ និងការដាក់សម្ពាធបរិស្ថាន

### ១.១.២.១.កម្រិតជីវភាពរស់នៅ

ភាពខុសគ្នានៃស្ថានភាពជីវភាព គឺជាកត្តាចម្បងដែលត្រូវបានគិតគូរនៅពេលមានការពិភាក្សាជុំវិញការជំរុញឱ្យមានការរៀបចំក្រុង។ កម្រិតជីវភាព និងប្រាក់បៀវត្សខ្ពស់នៅទីក្រុងជាកត្តាទាក់ទាញមនុស្សឱ្យមករស់នៅទីក្រុង។ ដរាបណាភាពខុសគ្នារវាងទីក្រុង និងជនបទមានគម្លាតខ្ពស់ ប្រជាពលរដ្ឋនៅជនបទនៅតែចង់ចូលមករស់នៅទីក្រុង។ ជាទូទៅកត្តាសេដ្ឋកិច្ច និងអត្រានិកម្មភាពខ្ពស់ជាកត្តាជំរុញចំណាកស្រុក ដោយសារតែពេលខ្លះការងារនៅជនបទនៅមាន

[២] បណ្ឌិត អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (២០១៨), ៧-៨។

កម្រិត ដូច្នេះទោះជាទទួលបានប្រាក់ខែទាបក៏ត្រូវតែបង្ខំចិត្តចំណាកស្រុកមកកាន់ទីក្រុងដែរ។ លើសពីនេះ នៅទីក្រុងមានប្រមូលផ្តុំដោយកត្តាសង្គម នយោបាយល្អប្រសើរ ខណៈពេលសេវាសុខាភិបាល និងអប់រំមានសម្បូរបែប រឹតតែធ្វើឱ្យអ្នករស់នៅមានអារម្មណ៍ថាមានសុវត្ថិភាពជាងកន្លែងណាៗទាំងអស់។[៣]

### ១.១.២.២.ការដាក់សម្ពាធបរិស្ថាន

សម្ពាធដ៏ធំបំផុតរបស់ប្រជាពលរដ្ឋនៅជនបទពាក់ព័ន្ធវិស័យបរិស្ថានគឺ កង្វះដីបង្កបង្កើនផលដើម្បីធ្វើកសិកម្ម។ ករណីនេះកើតមានច្រើនក្នុងករណីដែលដីរបស់ពួកគេទទួលបានពីដូនតាឪពុកម្តាយរបស់ខ្លួនត្រូវបានពួកគេចែកឱ្យកូនៗអស់។ ចំណែកផ្ទៃដីដែលនៅសល់មានទំហំតូចមិនសមល្មមសម្រាប់ធ្វើកសិកម្ម ឬ បង្កបង្កើនផលដំណាំផ្សេងឡើយ ហើយពេលខ្លះស្ថានភាពដីនោះមានលក្ខណៈខ្សោះ និងគ្មានជីវជាតិទៀត។ ប្រសិនបើក្រឡេកទៅមួយជ្រុងទៀត ចំពោះប្រជាពលរដ្ឋក្រីក្រនៅពេលដែលគាត់មានដីគ្រប់គ្រាន់ហើយ តែគាត់បែរជាកង្វះប្រព័ន្ធធារាសាស្ត្រស្រោចស្រព និងជីកសិកម្មសម្រាប់បង្កបង្កើនផលបានគ្រប់គ្រាន់ទៅវិញករណីនេះច្រើនកើតនៅប្រទេសកំពុងអភិវឌ្ឍក្នុងតំបន់មេគង្គក្រោម។[៤]

## ១.២.ស្ថានភាពទូទៅនៃក្រុងច្បារមន

### ១.២.១.ទីតាំងភូមិសាស្ត្រ និងតំបន់ទាក់ទាញ

### ១.២.១.១.ទីតាំងភូមិសាស្ត្រ

ក្រុមច្បារមន គឺជាក្រុងមួយក្នុងខេត្តកំពង់ស្ពឺ។ ក្រុងនេះមានទីតាំងស្ថិតនៅទិសខាងលិចទីរួមខេត្តកំពង់ស្ពឺ ដែលមានចម្ងាយប្រមាណ ៣ គីឡូម៉ែត្រពីសាលាខេត្ត។ ក្រុងមានផ្ទៃដីសរុប ចំនួន ១២៥.០៦ គីឡូម៉ែត្រការេ និងមានសណ្ឋានដីជាតំបន់ខ្ពង់រាប ដែលមានប្រជាពលរដ្ឋភាគច្រើនប្រមាណ ៨៥% ប្រកបរបរកសិកម្មជាចម្បង រីឯក្រៅពីនោះមានមុខរបរអាជីវកម្ម កម្មកររោងចក្រកសិដ្ឋានចិញ្ចឹមសត្វ និងសិប្បកម្មខ្នាតតូចជាលក្ខណៈគ្រួសារខ្លះៗ។ ក្រុងមានប្រព័ន្ធធារាសាស្ត្រជាប្រឡាយមេចំនួន ០២ ខ្សែ គឺប្រឡាយមេរលាំងជ្រៃខាងត្បូង និងប្រឡាយមេរលាំងជ្រៃខាងជើងដែលបានផ្តល់អំណោយផលសម្រាប់ការស្រោចស្រពស្រែ ចម្ការ ទាំងរដូវប្រាំង និងរដូវវស្សា ប៉ុន្តែនៅមានភូមិមួយចំនួនទៀត មិនទាន់មានប្រព័ន្ធធារាសាស្ត្រល្អប្រសើរសម្រាប់ស្រោចស្រពនៅឡើយ។ ភូមិទាំងនោះមានទំនប់ប្រឡាយដែរ ប៉ុន្តែទំនប់ប្រឡាយទាំងនោះមានការខូចខាត មិនទាន់បានជួសជុល និងស្តារឡើងវិញដែលជាបុព្វហេតុធ្វើឱ្យទិន្នផលស្រូវនៅមានកម្រិត។

---

[៣] បណ្ឌិត អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (២០១៨), ៨-៩។

[៤] បណ្ឌិត អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (២០១៨), ៩។

ក្រុងនេះ មានព្រំប្រទល់ព័ទ្ធជុំវិញដោយស្រុកសំរោងទង ដោយក្នុងនោះ៖

- ខាងកើតទល់នឹង ឃុំវល្លិសរ ស្រុកសំរោងទង
- ខាងត្បូងទល់នឹង ឃុំស្គុះ ស្រុកសំរោងទង
- ខាងលិចទល់នឹង ឃុំការហែង ស្រុកសំរោងទង
- ខាងជើងទល់នឹង ឃុំខ្វង់ក្រាំង ស្រុកសំរោងទង។

**១.២.១.២.តំបន់ទាក់ទាញ**

- **រមណីយដ្ឋានវប្បធម៌ និងធម្មជាតិអំពែភ្នំ** ៖ មានទីតាំងស្ថិតនៅក្នុងភូមិតាំងទន្លេ និងភូមិអំពែភ្នំ សង្កាត់សុព័រទេព និងសង្កាត់ស្វាយក្រវ៉ាន់ ដែលមានចម្ងាយ ៤៨ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ រួចបត់ឆ្វេង ២ គីឡូម៉ែត្រ នឹងដល់រមណីយដ្ឋាននេះ។ រមណីយដ្ឋាននេះបានរំលេចនូវទេសភាពនៃទឹកស្ទឹងឆ្លងកាត់រួមផ្សំដើមឈើតូចធំដុះប្រជ្រៀតគ្នាតាមដងស្ទឹង បង្កើតបានជាទេសភាពគួរឱ្យចង់គយគន់ក្រៃលែង ហើយនៅជើងភ្នំអំពែភ្នំមានស្ពានយោលមួយឆ្លងកាត់ពីត្រើយម្ខាងទៅត្រើយម្ខាងទៀត ដើម្បីតភ្ជាប់ពីភូមិតាំងទន្លេរបស់សង្កាត់សុព័រទេពទៅភូមិអំពែភ្នំរបស់សង្កាត់ស្វាយក្រវ៉ាន់។ នៅរដូវប្រាំងបើយើងឈរពីលើស្ពានយោលសម្លឹងចុះទៅបាតស្ទឹង នោះយើងនឹងបានឃើញទឹកស្ទឹងហូររិចៗគេចផ្ទាំងថ្ម និងពំនូកខ្សាច់ដោយមានហ្វូងចង្វាតូចៗហែលប្រដេញគ្នាឆ្វាត់ឆ្វែង និងជាយូរៗម្តងគេសង្កេតឃើញមានហ្វូងសត្វស្វានាំគ្នាចុះងូតទឹកបាតស្ទឹងយ៉ាងសប្បាយរីករាយ។ រីឯនៅរដូវវស្សាវិញបើយើងឈរនៅលើស្ពានយោលសម្លឹងចុះទៅស្ទឹងវិញនោះ យើងនឹងបានឃើញខ្សែទឹកហូរយ៉ាងខ្លួលខ្លាញ់បែកពពុះគួរឱ្យព្រឺខ្លាចក្រៃលែង ដែលអ្នកទេសចរមួយចំនួនឈរលើស្ពានសឹងមិនសម្លឹងចុះទឹកឡើយ។ នៅត្រើយខាងត្បូងស្ទឹង យើងនៅសង្កេតឃើញមានវត្តចាស់បុរាណមួយនៅលើកូនភ្នំដែលជាទីសក្ការៈរបស់ប្រជាពលរដ្ឋទៅធ្វើបុណ្យទានតាមប្រពៃណីជាតិ។ នៅតំបន់អំពែភ្នំគេអាចទៅងូតទឹក ឆ្លងស្ពានយោល និងអង្គុយលេងកម្សាន្តតាមតូបនានា សម្រាកតាមមាត់ស្ទឹងដើម្បីលំហែអារម្មណ៍ ហើយនៅតាមតូបនីមួយៗគេអាចធ្វើការទិញម្ហូបប្រចាំតំបន់យកមកពិសាបានយ៉ាងឆ្ងាញ់ផងដែរ។

- **សួនច្បារខេត្តកំពង់ស្ពឺ** ៖ សួននេះចាប់ផ្តើមកសាងតាំងពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៤ និងបញ្ចប់ការសាងសងនៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ ហើយនៅលើសួននេះមានវិមានតម្កល់រូបសំណាកសម្តេចព្រះសង្ឃរាជជួនណាតជោតញ្ញាណោ ដោយមានកម្ពស់ ១៩,៥៣ ម៉ែត្រ និងបាតក្រោមទំហំ ៣៩,៥៣ ម៉ែត្រ ដែលបានដឹកនាំកសាងដោយរដ្ឋបាលខេត្តកំពង់ស្ពឺ។ បន្ថែមពីនេះក៏មានការកសាងនូវវេទិកាអុំទូក ស៊ីមតម្កល់សិលាចារឹក កន្លែងហាត់ប្រាណ បន្ទប់ទឹកសាធារណៈ ជាដើម ដែលអាចងាយស្រួលឱ្យប្រជាពលរដ្ឋមកហាត់ប្រាណ និងដើរលេងកម្សាន្ត ព្រមទាំងងាយស្រួល

ដល់ប្រជាពលរដ្ឋលក់ដូរម្ហូបអាហារ ដើម្បីអាចរកប្រាក់ចំណូលយកមកផ្គត់ផ្គង់ជីវភាពគ្រួសារ និងបានជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងក្រុងបានមួយចំនួនផងដែរ។

### ១.២.២.រដ្ឋបាលក្រុង

#### ១.២.២.១.រដ្ឋបាលដែនដី

ក្រុងច្បារមន មានផ្ទៃដីសរុប ចំនួន ១២៥.០៦ គីឡូម៉ែតការេ។ ក្រុងនេះ មាន ៥ សង្កាត់ ដែលបែងចែកជា ៥៦ ភូមិ និងមានប្រជាជនសរុប ចំនួន ១០,៨៦០ គ្រួសារ ក្នុងនោះមានគ្រួសារអចិន្ត្រៃយ៍ ចំនួន ១០,៧៩១ គ្រួសារ និងគ្រួសារបណ្តោះអាសន្ន ចំនួន ៦៩ គ្រួសារ។ ប្រជាជនសរុបមាន ចំនួន ៤៧,៩៧៩ នាក់ ក្នុងនោះប្រជាជនជាស្ត្រី ចំនួន ២៣,២០២ គ្រួសារ។[៥]

- **សង្កាត់ច្បារមន** ៖ មានទីតាំងស្ថិតនៅភាគខាងជើងឆៀងខាងលិចនៃក្រុមច្បារមន។ សង្កាត់នេះមាន ចំនួន ១៣ ភូមិ គឺ ភូមិត្រពាំងលើក ភូមិពេជ្យសង្វារ ភូមិអង្គប្រាសាទ ភូមិច្បារមន ភូមិបុរីកម្មករ ភូមិខ្ទមក្រាំង ភូមិភ្នំដី ភូមិសំបូរ ភូមិចំការដូង ភូមិតាម៉ុល ភូមិផ្គង់ ភូមិសំរោង និងភូមិព្រៃស្លឹក។
- **សង្កាត់កណ្តោលដុំ** ៖ មានទីតាំងស្ថិតនៅភាគខាងលិចឆៀងខាងត្បូងនៃក្រុងច្បារមន។ សង្កាត់នេះមាន ចំនួន ១០ ភូមិ គឺ ភូមិថ្មី ភូមិកោះរៀន ភូមិរំលោង ភូមិពង្រ ភូមិផ្សារសាមគ្គី ភូមិញរ ភូមិកណ្តោលដុំ ភូមិត្រពាំងព្រះ ភូមិកាប់ទូក និងភូមិស្រែថ្នល់។
- **សង្កាត់រកាធំ** ៖ មានទីតាំងស្ថិតនៅភាគខាងជើងឆៀងខាងកើតនៃក្រុងច្បារមន។ សង្កាត់នេះមាន ចំនួន ១២ ភូមិ គឺ ភូមិក្រាំងពលទេព ភូមិពាណិជ្ជកម្ម ភូមិបុរីកម្មករ ភូមិសំណង់ ភូមិមុខខេត្ត ភូមិស្មោទី១ ភូមិអង្គសេរី ភូមិថ្មី ភូមិទួលផ្នង់ ភូមិខោប ភូមិរកាធំ និងភូមិត្រពាំងលើក។
- **សង្កាត់សុព័រទេព** ៖ មានទីតាំងស្ថិតនៅភាគខាងកើតនៃក្រុងច្បារមន។ សង្កាត់នេះមាន ចំនួន ១០ ភូមិ គឺ ភូមិតាំងទន្លេ ភូមិរំលោង ភូមិថ្លុកឈើទាល ភូមិត្រាចជ្រុំ ភូមិប៉ែលហែល ភូមិក្រងផ្កា ភូមិរំលោងប្រយ្លះ ភូមិព្រែកន្ទាច ភូមិស្មោរទី២ និងភូមិរលាំងសង្កែ។
- **សង្កាត់ស្វាយក្រវ៉ាន់** ៖ មានទីតាំងស្ថិតនៅភាគខាងកើតឆៀងខាងត្បូងនៃក្រុងច្បារមន ។ សង្កាត់នេះមាន ចំនួន ១១ ភូមិ គឺ ភូមិស្គុះ ភូមិដក់ពរ ភូមិស្វាយក្រវ៉ាន់ ភូមិទួលគោក ភូមិផ្សារចាស់ ភូមិថ្នល់ចាស់ ភូមិព្រៃក្តី ភូមិត្រស់ ភូមិអំពែភ្នំ ភូមិត្រស់សាលា និងភូមិកំណាប់។

---

[៥] សាលាក្រុងច្បារមន, *របាយការណ៍ត្រីមាសទី១ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងច្បារមន*, លេខ០៤/១៨រ.ប.ក (កំពង់ស្ពឺ៖ សាលាក្រុងច្បារមន, ២៣ មីនា ២០១៧), ២។

### ១.២.២.២.តួនាទី ភារកិច្ចក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុង

#### ក.ក្រុមប្រឹក្សាក្រុង

ក្រុមប្រឹក្សាក្រុង ដែលបានបង្កើតឡើងដោយការបោះឆ្នោតស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ គឺជាតំណាងសាធារណៈជាអ្នកការពារ និងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។[៦]

- **សិទ្ធិអំណាចរបស់ក្រុមប្រឹក្សា ៖** ក្រុមប្រឹក្សាមានសិទ្ធិអំណាច ២ គឺ៖
  - សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និង
  - សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងប្រតិបត្តិ។

ក្រុមប្រឹក្សាក្រុងត្រូវប្រើប្រាស់អំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ខ្លួនដោយផ្អែកតាមគោលការណ៍ បែបបទ និងនីតិវិធីដែលកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។[៧]

ប្រធានក្រុមប្រឹក្សាក្រុង ក្នុងនាមក្រុមប្រឹក្សាក្រុងរបស់ខ្លួន មានសិទ្ធិចុះហត្ថលេខា និងប្រថាប់ត្រារដ្ឋបាលក្រុងលើ៖

- ដីកា ឬសេចក្តីសម្រេចដែលក្រុមប្រឹក្សាក្រុងបានអនុម័តរួច
- សេចក្តីសម្រេចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារតាមការសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាក្រុង
- កំណត់ហេតុប្រជុំដែលអង្គប្រជុំក្រុមប្រឹក្សាក្រុងបានអនុម័ត
- សំណើដកហូតអភិបាលក្រុង ឬអភិបាលរងក្រុងចេញពីមុខតំណែងតាមការសម្រេចពីក្រុមប្រឹក្សាក្រុង តាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ១៥២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតអញ្ជើញប្រជុំក្រុមប្រឹក្សាក្រុង
- ប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាក្រុងសម្រាប់រយៈពេល ១២ខែ
- សំណើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាក្រុង
- កិច្ចការដទៃទៀតតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។[៨]

---

[៦] អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ១៤ ធ្នូ ២០០៩, មាត្រា៦ (ចាប់ពីពេលនេះតទៅហៅថាអនុក្រឹត្យលេខ២១៦អនក្រ.បក)។

[៧] អនុក្រឹត្យលេខ២១៦អនក្រ.បក, មាត្រា១៦ កថាខណ្ឌ១។

[៨] អនុក្រឹត្យលេខ២១៦អនក្រ.បក, មាត្រា១៣ កថាខណ្ឌ១។

គណៈអភិបាលក្រុង ត្រូវជួយក្រុមប្រឹក្សាក្រុងរបស់ខ្លួនក្នុងការរៀបចំឯកសារខាងលើនេះ លើកលែងតែឯកសារសម្រាប់រៀបចំកិច្ចប្រជុំទាក់ទងនឹងសំណើដកហូតអភិបាលក្រុង ឬអភិបាលរងក្រុងចេញពីមុខតំណែង។[៩]

- **របៀបរបបការងាររបស់ក្រុមប្រឹក្សាក្រុង ៖** ក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួន ក្រុមប្រឹក្សាក្រុងត្រូវពិនិត្យពិចារណាលើចំណុចសំខាន់ៗមួយចំនួន ដែលពាក់ព័ន្ធនឹងរបៀបរបបអនុវត្តការងារដូចខាងក្រោម៖

  - ក្រុមប្រឹក្សាក្រុង ត្រូវបំពេញមុខងារ និងភារកិច្ចរបស់ខ្លួនដោយធ្វើសេចក្ដីសម្រេចខាងបញ្ញត្តិ និងសេចក្ដីសម្រេចខាងប្រតិបត្តិ តាមរយៈដីកា និងសេចក្ដីសម្រេចនានាក្នុងអង្គប្រជុំក្រុមប្រឹក្សារបស់ខ្លួន និងត្រូវធានាថាសេចក្ដីសម្រេចទាំងនោះត្រូវបានអនុវត្តដោយមានការតាមដាន និងវាយតម្លៃជាប្រចាំ។[១០]
  - ក្រុមប្រឹក្សាក្រុង អាចចាត់ឱ្យគណៈកម្មាធិការណាមួយ ឬមួយចំនួនដែលតម្រូវឱ្យបង្កើតឡើងដោយច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬអាចបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានា ដើម្បីស្រាវជ្រាវរៀបចំសេចក្ដីព្រាងដីកា ឬសេចក្ដីព្រាងសេចក្ដីសម្រេចតាមការចាំបាច់។ ក្នុងករណីនេះ គណៈអភិបាលក្រុងត្រូវដឹកនាំនាយករដ្ឋបាលសាលាក្រុង និងការិយាល័យពាក់ព័ន្ធនៃសាលាក្រុង ដើម្បីផ្ដល់ការគាំទ្រផ្នែកច្បាប់ បច្ចេកទេស និងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារខាងលើ។[១១]
  - ក្រុមប្រឹក្សាក្រុង ត្រូវចាត់ឱ្យអភិបាលក្រុងចាត់ចែងផ្សព្វផ្សាយជាសាធារណៈជាបន្ទាន់នូវដីកា ឬសេចក្ដីសម្រេចទាំងឡាយដែលក្រុមប្រឹក្សាក្រុងបានអនុម័តរួច លើកលែងតែមានការកំណត់ផ្សេងពីនេះ ព្រមទាំងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។[១២]
  - ក្នុងករណីកិច្ចការណាមួយ ដែលជាតម្រូវការចាំបាច់នៃមូលដ្ឋានរបស់ខ្លួន ហើយដែលកិច្ចការនោះ ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តមិនបានចែងអំពីបែបបទ និងនីតិ

[៩] អនុក្រឹត្យលេខ២១៦អនក្រ.បក, មាត្រា១៣ កថាខណ្ឌ២។
[១០] អនុក្រឹត្យលេខ២១៦អនក្រ.បក, មាត្រា១០។
[១១] អនុក្រឹត្យលេខ២១៦អនក្រ.បក, មាត្រា១២ កថាខណ្ឌ១។
[១២] អនុក្រឹត្យលេខ២១៦អនក្រ.បក, មាត្រា១២ កថាខណ្ឌ៤។

វិធីក្នុងការប្រើប្រាស់អំណាចបញ្ញត្តិ ឬអំណាចប្រតិបត្តិរបស់ខ្លួន ក្រុមប្រឹក្សាក្រុងត្រូវចាត់ឱ្យគណៈអភិបាលក្រុងធ្វើការសិក្សាស្រាវជ្រាវ រៀបចំបែបបទ និងនីតិវិធីសមស្របដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពដាក់ជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័ត ដើម្បីដោះស្រាយកិច្ចការទាំងនោះ ឬអាចស្នើសុំយោបល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធនានាធ្វើការបញ្ជាក់នូវបែបបទ នីតិវិធី ដើម្បីដោះស្រាយកិច្ចការទាំងនោះ។[១៣]

  - ក្នុងករណីកិច្ចការណាមួយ ដែលច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីបែបបទ និងនីតិវិធីដែរ ប៉ុន្តែបែបបទ និងនីតិវិធីនោះចែងមិនច្បាស់លាស់ ឬមិនស្របនឹងស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន ហើយដែលក្រុមប្រឹក្សាក្រុងមិនអាចអនុវត្តបាន ក្រុមប្រឹក្សាក្រុងត្រូវចាត់ឱ្យគណៈអភិបាលក្រុងធ្វើសំណើមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវផ្អែកតាមយន្តការនៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ធ្វើការសម្របសម្រួលជាមួយរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពាក់ព័ន្ធដើម្បីពិនិត្យ និងដោះស្រាយករណីនេះ។[១៤]

- **កិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុង ៖** កិច្ចប្រជុំរបស់ក្រុមប្រឹក្សាក្រុងមាន ២ ប្រភេទ៖
  - **កិច្ចប្រជុំសាមញ្ញ ៖** ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញយ៉ាងហោចណាស់ចំនួន ១២ដងក្នុងមួយឆ្នាំ។
  - **កិច្ចប្រជុំវិសាមញ្ញ ៖** ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេស។

កិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញអាចយកជាការបាន លុះត្រាតែកិច្ចប្រជុំនេះប្រព្រឹត្តទៅត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាក្រុង។ សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើងមិនស្របនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាក្រុង ឬរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តនានា សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។[១៥]

---

[១៣] អនុក្រឹត្យលេខ២១៦អនក្រ.បក, មាត្រា១៦ កថាខណ្ឌ២។
[១៤] អនុក្រឹត្យលេខ២១៦អនក្រ.បក, មាត្រា១៦ កថាខណ្ឌ៣។
[១៥] អនុក្រឹត្យលេខ២១៦អនក្រ.បក, មាត្រា១១ កថាខណ្ឌ១ និងកថាខណ្ឌ២។

រាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាក្រុងត្រូវធ្វើសេចក្ដីសម្រេចខាងបញ្ញត្តិ ឬធ្វើសេចក្ដីសម្រេចខាងប្រតិបត្តិ ដែលជាគោលការណ៍ គោលនយោបាយរបស់រដ្ឋបាលក្រុង និងជាវិធានការ បែបបទនីតិវិធីចាត់ចែងការងារ តាមការចាំបាច់ដែលទាក់ទងនឹង៖

- o ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មីដែលស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- o ការអនុវត្តមុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- o ការអនុវត្តមុខងារជាជម្រើសរបស់ក្រុមប្រឹក្សាក្រុង
- o ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ រួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នា ក្រសួង ស្ថាប័ន ឬមន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនានា
- o ថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលក្រុង
- o បញ្ហាហិរញ្ញវត្ថុផ្សេងទៀតរបស់ក្រុមប្រឹក្សាក្រុង
- o ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងការរៀបចំគណៈកម្មាធិការ ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- o ការបែងចែកភារកិច្ចដល់សមាជិកក្រុមប្រឹក្សាក្រុង ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ និងទទួលតាមដានការងារនានា តាមតម្រូវការរបស់ក្រុមប្រឹក្សាក្រុង
- o ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលក្រុង
- o ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជន ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- o សមិទ្ធផល និងបញ្ហាប្រឈមនៃកិច្ចការនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- o កិច្ចការផ្សេងៗទៀតដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។

ក្រៅពីកិច្ចការដែលក្រុមប្រឹក្សាក្រុងត្រូវធ្វើការសម្រេចដូចរៀបរាប់ខាងលើ ក្រុមប្រឹក្សាក្រុងអាចធ្វើការសម្រេចក្នុងកិច្ចការប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ខ្លួននូវកិច្ចការផ្សេងៗទៀតរួមមាន៖

- ការកោះអញ្ជើញអភិបាលក្រុង ឬអភិបាលរងក្រុង ឬគណៈអភិបាលក្រុងទាំងមូល ឬបុគ្គលដែលពាក់ព័ន្ធមកសាកសួរ អំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាក្រុង ឬហេតុការណ៍ណាមួយដែលកើតមានក្នុងក្រុង ឬការដោះស្រាយបញ្ហាបន្ទាន់ និងពិសេសណាមួយ ព្រមទាំងកិច្ចការផ្សេងៗទៀត ដែលពាក់ព័ន្ធដល់រដ្ឋបាលក្រុង
- ការសម្រេចឱ្យមានការសិក្សា ស្រាវជ្រាវ ឬការស៊ើបអង្កេតលើករណីទាំងឡាយណាដែលក្រុមប្រឹក្សាក្រុងយល់ឃើញថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង និងការសម្រេចឱ្យធ្វើការផ្សព្វផ្សាយលទ្ធផលនៃការសិក្សា ស្រាវជ្រាវ ឬការធ្វើអង្កេតនេះ ព្រមទាំងណែនាំដល់គណៈអភិបាលក្រុង អំពីវិធានការដោះស្រាយតាមលទ្ធផលនៃការធ្វើអង្កេតនេះ
- ការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចដល់ក្រុមប្រឹក្សាសង្កាត់ និងការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់
- ការពិនិត្យស្រាវជ្រាវ និងការធ្វើសេចក្តីរាយការណ៍ទៅក្រសួងមហាផ្ទៃក្នុងករណីមានការរំលោភអំណាចកើតឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការពិនិត្យ និងដោះស្រាយចំពោះទង្វើមិនស្របច្បាប់ដែលប្រព្រឹត្តដោយក្រុមប្រឹក្សាក្រុង ឬសមាជិកក្រុមប្រឹក្សាក្រុង ឬគណៈអភិបាលក្រុង ឬអភិបាលក្រុង ឬអភិបាលរងក្រុង ឬដោយបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
- ការពិនិត្យ និងចាត់វិធានការដោះស្រាយវិវាទនៅមូលដ្ឋាន ស្របទៅតាមច្បាប់ និងនីតិវិធីជាធរមាន
- ការពិនិត្យ និងដោះស្រាយឱ្យបានសមស្របអំពីសំណូមពរ ឬការតវ៉ានានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ដែលរៀបចំដោយគណៈអភិបាលក្រុង
- បញ្ហាផ្សេងៗទៀតដែលតម្រូវដោយច្បាប់ លិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបញ្ហានានាដែលក្រុមប្រឹក្សាក្រុង និងគណៈអភិបាលក្រុងយល់ឃើញថាមានការចាំបាច់។[១៣]

[១៣] គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, *សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលក្រុង* (ក្រសួងមហាផ្ទៃ, ២០១១), ១០-១៦។

## ខ.គណៈអភិបាលក្រុង

ក្រុងនីមួយៗត្រូវមានគណៈអភិបាលក្រុងមួយ ដែលរួមមានអភិបាលក្រុង និងអភិបាលរងក្រុងមួយចំនួន ដែលត្រូវបានតែងតាំងឡើងស្របតាមលក្ខខណ្ឌនៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ អភិបាលក្រុង អភិបាលរងក្រុងមិនមែនជាសមាជិកក្រុមប្រឹក្សាក្រុងឡើយ។

- **តួនាទីរបស់គណៈអភិបាលក្រុង ៖** គណៈអភិបាលក្រុងមានតួនាទី ភារកិច្ចដូចខាងក្រោម៖
  - o គណៈអភិបាលក្រុង ត្រូវធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្ដល់យោបល់ជូនក្រុមប្រឹក្សាក្រុងអំពីកិច្ចការនានា ដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាក្រុង ដើម្បីក្រុមប្រឹក្សាក្រុងធ្វើការពិភាក្សា អនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនឹង៖
    - ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាក្រុង និងរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ
    - ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ ឬបានផ្ទេរស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
    - ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ
    - ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងការធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
    - គម្រោងថវិកាប្រចាំឆ្នាំ
    - ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ក្រុង
    - ការបង្កើត ការកែសម្រួល ឬការរំសាយការិយាល័យនានា
    - ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក
    - ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុសម្រាប់ការិយាល័យ និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង
    - ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង និងបុគ្គលរបស់ក្រុមប្រឹក្សាក្រុង
    - ការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដាក់ជូនក្រុមប្រឹក្សាក្រុងពិនិត្យ និងអនុម័តមិនឱ្យលើសពី៤៥ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗដែលពាក់ព័ន្ធនឹង៖

១.ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញដោយក្រុមប្រឹក្សាក្រុង និងសកម្មភាពលទ្ធផលនៃការអនុវត្ត

២.របាយការណ៍ហិរញ្ញវត្ថុ

៣.ការវាយតម្លៃអំពីការបំពេញការងាររបស់គណៈអភិបាលក្រុង និងបុគ្គលិករបស់ក្រុមប្រឹក្សាក្រុង

៤.វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង

៥.វិធានការចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ កិច្ចការផ្សេងៗទៀត ដែលក្រុមប្រឹក្សាក្រុងយល់ឃើញថាចាំបាច់ ត្រូវដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន

- របាយការណ៍ប្រចាំខែ ត្រីមាស និងឆមាស
- ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានា តាមការចាំបាច់ ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាក្រុង
- ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជា ការរៀបចំក្តារព័ត៌មាន ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានា ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់សង្កាត់
- ការធ្វើប្រតិភូកម្មមុខងារ ភារកិច្ច និងការគាំទ្រដល់ក្រុមប្រឹក្សាសង្កាត់
- កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សាក្រុងរបស់ខ្លួន

o នៅពេលបានទទួលរបាយការណ៍ ឬព័ត៌មានអំពីការរំលោភអំណាច គណៈអភិបាលក្រុងត្រូវធ្វើការស៊ើបអង្កេតជាបន្ទាន់។ ប្រសិនបើរកឃើញថាមានការរំលោភអំណាចពិតប្រាកដមែន គណៈអភិបាលក្រុងត្រូវធ្វើសេចក្តីរាយការណ៍ជាបន្ទាន់ទៅក្រុមប្រឹក្សាក្រុង និងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តធ្វើ សេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ អភិបាលក្រុងមានតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងក្រុង។ ក្នុងតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិបាលក្រុងត្រូវៈ

- ថែរក្សាសន្តិសុខ សណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងក្រុងអំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធិមនុស្ស ចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងក្រុង
- ធ្វើជាប្រធានគណៈបញ្ជាការឯកភាពក្រុង ក្នុងការដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធនានា និងសង្កាត់នៅក្នុងក្រុង ដើម្បីធានារក្សាសន្តិសុខ សណ្ដាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងក្រុង
- ណែនាំដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅក្រុងឱ្យអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវស្របតាមគោលនយោបាយជាតិ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងការិយាល័យ អង្គភាព និងទីភ្នាក់ងារនីមួយៗនោះ
- សម្របសម្រួលតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុង ក្នុងការឆ្លើយតបតម្រូវការជាអាទិភាពនៅមូលដ្ឋាន។ ក្នុងករណីកិច្ចការទាំងឡាយណាដែលមានការពាក់ព័ន្ធច្រើនវិស័យ អភិបាលក្រុងត្រូវធ្វើការសម្របសម្រួលការិយាល័យ អង្គភាព ទីភ្នាក់ងារពាក់ព័ន្ធ ដើម្បីសហការគ្នាអនុវត្តកិច្ចការនោះ ដោយផ្អែកតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងតម្រូវការអាទិភាពរបស់មូលដ្ឋាន។ តាមរយៈគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង អភិបាលក្រុងត្រូវសម្របសម្រួលតម្រង់ទិស ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដែលប្រចាំនៅក្នុងការធ្វើសមាហរណកម្មផែនការ និងថវិការបស់ខ្លួនទៅក្នុងផែនការ និងថវិការបស់ក្រុមប្រឹក្សាក្រុង
- ពិនិត្យ វាយតម្លៃ ផ្ដល់មូលវិចារណ៍ និងដាក់ពិន្ទុប្រធានការិយាល័យ អង្គភាពនៃក្រសួង ស្ថាប័ននានាដែលប្រចាំការនៅក្នុងក្រុង
- ពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាក្រុងជាមុន ក្នុងការផ្ដល់យោបល់លើបេក្ខភាពដែលស្នើតែងតាំងជាប្រធានការិយាល័យ និងអង្គភាពនៃក្រសួង ស្ថាប័ននានាប្រចាំនៅក្នុងក្រុងរបស់ខ្លួន។ ក្នុងករណីមិនគាំទ្របេក្ខជនដែលស្នើតែងតាំងខាងលើនេះ អភិបាលក្រុងត្រូវវាយការណ៍ជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ច្បាស់ពីហេតុផលនៃការមិនគាំទ្រនេះជូនអភិបាលខេត្ត ដើម្បីអភិបាលខេត្តធ្វើការ

សម្របសម្រួលជាមួយប្រធាន មន្ទីរ អង្គភាពសាមីជាមុន មុននឹងធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី

- រាយការណ៍ជាលាយលក្ខណ៍អក្សរ និងជាបន្ទាន់ទៅអភិបាលខេត្តក្នុងករណីពិនិត្យឃើញមានភាពមិនប្រក្រតី ដែលកើតមានក្នុងការិយាល័យ អង្គភាព និងទីភ្នាក់ងារណាមួយរបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្នុងក្រុងរបស់ខ្លួន ឬក្នុងករណីប្រធានការិយាល័យ ប្រធានអង្គភាព និងអ្នកទទួលខុសត្រូវនៃការិយាល័យអង្គភាពបានប្រព្រឹត្តខុសឆ្គងពីតួនាទី និងភារកិច្ចរបស់ខ្លួន។ អភិបាលខេត្តត្រូវណែនាំដល់មន្ទីរ អង្គភាពខ្សែបណ្តោយសាមីនៅថ្នាក់ខេត្ត ដើម្បីស្រាវជ្រាវអំពីបញ្ហានេះ ឬអាចចាត់តាំងគណៈកម្មការ ឬក្រុមការងារ ដែលមានការចូលរួមពីរដ្ឋបាលក្រុងពាក់ព័ន្ធឱ្យធ្វើការស៊ើបអង្កេតលើករណីនេះជាបន្ទាន់ ដើម្បីធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នសាមី ដោះស្រាយស្របតាមនីតិវិធី
- មានសិទ្ធិស្នើជាលាយលក្ខណ៍អក្សរទៅអភិបាលខេត្ត ដើម្បីចាត់វិធានការផ្លាស់ប្តូរ ឬដកហូតពីមុខតំណែងនូវប្រធានការិយាល័យ ឬប្រធានអង្គភាព ឬអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារណាមួយ របស់ក្រសួងស្ថាប័នដែលប្រព្រឹត្តខុសច្បាប់ ហើយដែលមិនអាចធ្វើយុត្តកម្មបាន។

❖ <u>បញ្ជាក់</u> ៖

១.ដើម្បីធានាឱ្យអភិបាលក្រុងអនុវត្តនូវភារកិច្ចខាងលើនេះ សេចក្តីរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុងត្រូវដាក់ជូនអភិបាលក្រុង ដើម្បីពិនិត្យ និងផ្តល់យោបល់។ ប្រសិនបើអភិបាលក្រុងឯកភាព អភិបាលក្រុងត្រូវចុះហត្ថលេខាលើរបាយការណ៍នោះ រួមជាមួយប្រធានការិយាល័យ អង្គភាព និងអ្នកទទួលខុសត្រូវនៃទីភ្នាក់ងារនោះ។

២.ចំពោះសេចក្តីរាយការណ៍ក្រៅពីនោះរបស់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រចាំនៅក្រុងត្រូវចម្លងជូនសាលាក្រុង។

- **របៀបរបបការងាររបស់គណៈអភិបាលក្រុង ៖** ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន គណៈអភិបាលក្រុង អភិបាលក្រុង អភិបាលរងក្រុងត្រូវពិនិត្យ ពិចារណាលើចំណុចសំខាន់មួយចំនួនដែលពាក់ព័ន្ធនឹងរបៀបរបបអនុវត្តការងារដូចខាងក្រោម៖

  - ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន អភិបាលក្រុងត្រូវគោរពតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការណែនាំ

របស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានា និងត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ ក្រសួងស្ថាប័ននានាស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

- ក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន និងការងារដទៃទៀតដែលខ្លួនយល់ឃើញថាចាំបាច់ អភិបាលក្រុងត្រូវយកការងារទាំងនោះមកពិគ្រោះពិភាក្សាក្នុងគណៈអភិបាលក្រុងរបស់ខ្លួនដោយឈរលើគោលការណ៍ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងការសម្រេច និងគោលការណ៍ណែនាំពីក្រុមប្រឹក្សាក្រុងរបស់ខ្លួន
- អភិបាលក្រុងត្រូវទទួលខុសត្រូវ ចំពោះមុខក្រុមប្រឹក្សាក្រុងអំពីសកម្មភាពការងារទាំងអស់របស់គណៈអភិបាលក្រុងរបស់ខ្លួន។ អភិបាលរងក្រុង ត្រូវទទួលខុសត្រូវចំពោះមុខអភិបាលក្រុងលើភារកិច្ចនានាដែលបានប្រគល់ជូន ហើយត្រូវរួមជាមួយអភិបាលក្រុងទទួលខុសត្រូវអមពីការសម្រេច និងសកម្មភាពក្នុងគណៈអភិបាលក្រុងរបស់ខ្លួន
- ដើម្បីធានាឱ្យបាននូវគោលការណ៍នៃការអនុវត្តការងារនេះ គណៈអភិបាលក្រុងត្រូវជួបប្រជុំប្រចាំអឌ្ឍមាស។ ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗជាការប្រជុំប្រចាំខែ។ ក្រៅពីការប្រជុំប្រចាំអឌ្ឍមាស និងការប្រជុំប្រចាំខែ គណៈអភិបាលក្រុងអាចកោះប្រជុំតាមការចាំបាច់។ រៀងរាល់កិច្ចប្រជុំទាំងអស់នេះត្រូវមានកំណត់ហេតុនៃកិច្ចប្រជុំ
- គណៈអភិបាលក្រុងត្រូវប្រជុំពិភាក្សា ដើម្បីបែងចែកភារកិច្ចដល់អភិបាលក្រុង និងអភិបាលរងក្រុង ហើយសុំការសម្រេចពីក្រុមប្រឹក្សាក្រុងរបស់ខ្លួន។ អភិបាលរងក្រុងដែលទទួលបានការបែងចែកភារកិច្ចនេះ ត្រូវទទួលខុសត្រូវអំពីសកម្មភាពរបស់ខ្លួនចំពោះមុខអភិបាលក្រុង
- អភិបាលក្រុង ត្រូវចុះហត្ថលេខាលើលិខិតស្នាមរដ្ឋបាលសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ ដើម្បីអនុវត្តសេចក្តីសម្រេចនៃក្រុមប្រឹក្សាក្រុងរបស់ខ្លួន លើកលែងតែលិខិតបទដ្ឋាន ដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាក្រុងចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាក្រុងរបស់ខ្លួន។ អភិបាលក្រុងអាចប្រគល់សិទ្ធិដល់អភិបាលរងក្រុងក្នុងការចុះហត្ថលេខាលើឯកសារលិខិតស្នាមរដ្ឋបាលចាំបាច់មួយចំនួន ក្នុងក្របខ័ណ្ឌនៃភារកិច្ចដែលបានបែងចែកជូនអភិបាលរងក្រុងនីមួយៗ។ ប៉ុន្តែអភិបាលក្រុងត្រូវ

ទទួលខុសត្រូវអំពីភាពត្រឹមត្រូវតាមច្បាប់ និងបែបបទ នីតិវិធីចំពោះឯកសារ លិខិតស្នាមដែលបានប្រគល់សិទ្ធិចុះហត្ថលេខាដល់អភិបាលរងក្រុង

- អភិបាលក្រុង មានសិទ្ធិដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខាពីអភិបាលរងក្រុងណាមួយ ដែលប្រើប្រាស់អំណាចនេះមិនស្របច្បាប់ និងមិនស្របតាមបែបបទនីតិវិធី។ ការប្រគល់ និងការដកហូតមកវិញនូវសិទ្ធិចុះហត្ថលេខានេះ អភិបាលក្រុងត្រូវរាយការណ៍ជូនក្រុមប្រឹក្សាក្រុងរបស់ខ្លួន
- ក្នុងករណីអភិបាលក្រុងអវត្តមាន អភិបាលក្រុងត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអភិបាលរងក្រុងមួយរូបឱ្យទទួលជាអភិបាលរងក្រុងស្តីទី។ ប្រសិនបើអភិបាលក្រុងអវត្តមានពុំមានការផ្ទេរសិទ្ធិ អភិបាលរងក្រុងដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃប្រកាសតែងតាំងអភិបាលរងនៃគណៈអភិបាលក្រុង ត្រូវធ្វើជាអភិបាលក្រុងស្តីទី។ ក្នុងករណីអភិបាលក្រុងស្តីទីអវត្តមាន អភិបាលខេត្តត្រូវចេញដីកា ដើម្បីប្រគល់ភារកិច្ចជូនអភិបាលរងក្រុងមួយរូបឱ្យទទួលជាអភិបាលក្រុងស្តីទី និងត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋបាលខេត្ត ដើម្បីរដ្ឋបាលខេត្តធ្វើសេចក្តីរាយការណ៍មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អភិបាលក្រុងស្តីទី ត្រូវរាយការណ៍រាល់កិច្ចការដែលបានអនុវត្តជូនអភិបាលក្រុងនៅពេលដែលអភិបាលក្រុងមានវត្តមានវិញ
- គណៈអភិបាលក្រុង ឬអភិបាលក្រុង ឬអភិបាលរងក្រុង ដែលបានសម្រេច និងឬដែលបានអនុវត្តកិច្ចការណាមួយផ្ទុយនឹងច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុងប្រឹក្សាក្រុង ហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សាក្រុង ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពឡើយ។ គណៈអភិបាលក្រុង ឬអភិបាលក្រុង ឬអភិបាលរងក្រុងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពខាងលើនេះ។[១៧]

---

[១៧] គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, *សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលក្រុង* (ក្រសួងមហាផ្ទៃ, ២០១១), ១៧-២៥។

# ជំពូកទី២
# ការរៀបចំក្រុងច្បាប់មនឱ្យមាន
# សោត័ណភាព និងសណ្តាប់ធ្នាប់

# ជំពូកទី២
# ការរៀបចំក្រុងច្បារមនឱ្យមានសោភ័ណភាព និងសណ្ដាប់ធ្នាប់

## ២.១.ការរៀបចំក្រុងច្បារមន

### ២.១.១.សោភ័ណភាព

#### ២.១.១.១.ពេលថ្ងៃ

##### ក.ការរៀបចំសណ្ដាប់ធ្នាប់ហេដ្ឋារចនាសម្ព័ន្ធ

ការរៀបចំកសាងសំណង់ ដូចជា សំណង់រោងចក្រ សហគ្រាស ស្ថានីយប្រេង ឃ្លាំងទំនិញ និងសំណង់បុរី លំនៅដ្ឋាន ផ្ទះល្វែង ផ្សារ មន្ទីរពេទ្យ សាលារៀន ជាដើម ត្រូវតែធ្វើឡើងដោយគោរព តាមស្តង់ដារដែលច្បាប់បានកំណត់។ រីឯការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវត្រូវអនុលោមតាម ច្បាប់ផ្លូវថ្នល់ត្រង់មាត្រា៣០ ដែលបានចែងថា ដើម្បីធានាដល់ការធ្វើចរាចរណ៍លើផ្លូវល្បឿនលឿន ផ្លូវជាតិ ផ្លូវខេត្ត ប្រកបដោយសុវត្ថិភាពរាល់សំណង់ដែលមានច្រកចេញចូលជាប់ផ្លូវថ្នល់ខាងលើ នេះត្រូវអនុវត្តដូចខាងក្រោម៖

- ការសាងសង់សំណង់ ដូចជា ស្ថានីយប្រេងឥន្ធនៈ ស្ថានីយហ្គាស កន្លែងលាងយានយន្ត យានដ្ឋាន ឬសំណង់ប្រហាក់ប្រហែលផ្សេងៗទៀត ដែលមានមនុស្សជួបជុំគ្នាមធ្យមត្រូវស្ថិត ក្នុងចម្ងាយយ៉ាងតិច ១៥ម៉ែត្រ ពីខ្សែបន្ទាត់ព្រំដីចំណីផ្លូវ។
- ការសាងសង់មជ្ឈមណ្ឌលពាណិជ្ជកម្ម ពហុកីឡដ្ឋាន ទីលានប្រកួត រោងមហោស្រព មន្ទីរ ពេទ្យ គ្រឹះស្ថានសិក្សា ការរៀបចំផ្សារ ផ្សារណាត់ ពិព័រណ៍ទំនិញ ឬកិច្ចការផ្សេងទៀតដែល មានមនុស្សជួបជុំគ្នាច្រើន ត្រូវស្ថិតក្នុងចម្ងាយយ៉ាងតិចបំផុត ៥០ម៉ែត្រ ពីខ្សែបន្ទាត់ព្រំដី ចំណីផ្លូវថ្នល់។
- ការកំណត់ដូចមានចែងក្នុងចំណុចទី១ និងទី២ ខាងលើនេះ មិនអនុវត្តចំពោះរាល់សំណង់ ដែលបានសាងសង់ពីមុនស្របតាមបទប្បញ្ញត្តិជាធរមានឡើយ។
- ការកំណត់ចម្ងាយដូចមានចែងនៅចំណុចទី១ និងទី២ ខាងលើចំពោះផ្លូវជនបទត្រូវកំណត់ ដោយអនុក្រឹត្យដោយឡែក។

បន្ថែមពីនេះទៅទៀត អាជ្ញាធរពាក់ព័ន្ធជួយពង្រឹងការផ្សព្វផ្សាយ ដល់មន្ត្រីជំនាញក្រោម ឱវាទ និងរឹតបន្តឹងការអនុញ្ញាតច្បាប់សាងសង់ ការត្រួតពិនិត្យនូវលក្ខខណ្ឌបច្ចេកទេសពាក់ព័ន្ធមុន នឹងផ្ដល់អាជ្ញាបណ្ណ និងការចុះត្រួតពិនិត្យទប់ស្កាត់ និងឱ្យរុះរើរាល់គម្រោងសាងសង់ណាដែលពុំ បានគោរពទៅតាមបញ្ញត្តិនៃច្បាប់។

ដើម្បីអាចរៀបចំហេដ្ឋារចនាសម្ព័ន្ធឱ្យកាន់តែមានសណ្ដាប់ធ្នាប់ លុះត្រាតែក្រុងនោះគោរពតាមប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លីនៃក្រុងនីមួយៗ ។ ប្លង់គោល គឺមានសារៈសំខាន់ជាខ្លាំងចំពោះនយោបាយនគរូបនីយកម្ម ឬ អាចនិយាយបានថាជាឯកសារដែលមិនអាចខ្វះបានក្នុងនយោបាយនគរូបនីយកម្មក៏ដូចជាការអភិវឌ្ឍប្រទេស។ លើសពីនេះទៅទៀត ប្លង់គោលនេះវាជាច្បាប់មួយដែលបានកំណត់រាល់ការសាងសង់សំណង់ទាំងអស់ត្រូវតែគោរពតាមប្លង់នេះជាដាច់ខាត ហើយមិនអាចមានអគារ ឬ សំណង់ណាមួយសាងសង់ដោយបំពានប្លង់នេះបានឡើយ បើមិនដូចនោះនឹងត្រូវទទួលរងនូវទណ្ឌកម្មនានាជាក់ជាមិនខាន។ ចំពោះប្លង់គោលនេះអាចលេចឡើងតាមរយៈ ២ រូបភាពគឺៈ

- **ប្លង់គោលសម្រាប់ខេត្ត ឬ ក្រុង ៖** ត្រូវរៀបចំដោយគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់រាជធានីភ្នំពេញ ឬអនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត ក្រុងនីមួយៗ ហើយប្លង់គោលនេះត្រូវតែមានការយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ និងត្រូវកំណត់ដោយអនុក្រឹត្យ។
- **ប្លង់គោលសម្រាប់តំបន់ពិសេស ៖** ត្រូវបានបង្កើតឡើង ដើម្បីការពារនូវបេតិកភណ្ឌ បរិស្ថាន និងដើម្បីធានាអភិវឌ្ឍសេដ្ឋកិច្ច។ ចំពោះតំបន់ពិសេសណាមួយដែលគណៈរដ្ឋមន្ត្រីបានកំណត់ គណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ មានភារៈរៀបចំប្លង់គោលនេះសម្រាប់ដាក់ជូនគណៈរដ្ឋមន្ត្រីអនុម័ត។

រីឯប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ក៏មានសារៈសំខាន់ដែរក្នុងនយោបាយនគរូបនីយកម្ម។ ប្លង់នេះត្រូវបានបង្កើត និងរៀបចំសម្រាប់ខេត្ត-ក្រុង ព្រមទាំងត្រូវមានការគោរពពីសំណាក់ឯកជនក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចសាធារណៈក្នុងការសាងសង់របស់ខ្លួន និងត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់អំពីតំបន់ដែលត្រូវបានប្រើប្រាស់សម្រាប់ការពារជាតិ កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម សិប្បកម្ម វប្បធម៌ ទេសចរណ៍ សាសនា ព្រមទាំងសំណង់នៃរដ្ឋបាល និងបរិក្ខារសាធារណៈ ម្យ៉ាងវិញទៀតប្លង់នេះកំណត់ផងដែរនូវលទ្ធភាពសម្រាប់សាងសង់។ ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់សម្រាប់រាជធានី និងខេត្ត-ក្រុងនីមួយៗត្រូវមានការទទួលយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ខេត្ត-ក្រុងរួច ត្រូវមានការយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ទៀត។ ប្លង់ទាំងអស់ត្រូវតែមានការទទួលគោរពពីឯកជនក៏ដូចជាអាជ្ញាធរសាធារណៈទាំងពួងផង។[១៨]

[១៨] បណ្ឌិត អ៊ុន សកក្កដា, *នីតិនគរូបនីយវិទ្យា* (២០១៨), ១៣៣-១៣៤។

**ខ.ការរៀបចំចរាចរណ៍**

ដើម្បីរៀបចំចរាចរណ៍ក្នុងក្រុងឱ្យបានល្អ លុះត្រាតែអាជ្ញាធរពាក់ព័ន្ធយកចិត្តទុកដាក់ធ្វើយ៉ាងណាកុំឱ្យមានការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ ហើយបញ្ហានេះគឺជាកង្វល់មួយដែលអាជ្ញាធរមូលដ្ឋានតែងតែរិះរកគ្រប់មធ្យោបាយ ដើម្បីធ្វើការយ៉ាងណាកាត់បន្ថយបញ្ហានេះឱ្យខានតែបាន តាមរយៈការចុះអប់រំប្រជាពលរដ្ឋនៅតាមមូលដ្ឋានឱ្យយល់កាន់តែច្បាស់អំពីមូលហេតុដែលនាំឱ្យមានគ្រោះថ្នាក់ចរាចរណ៍ និងការកកស្ទះចរាចរណ៍ ព្រមទាំងស្វែងរកដំណោះស្រាយដូចខាងក្រោម៖

- **កត្តាមនុស្ស** ៖ កត្តានេះត្រូវបានគេសង្កេតឃើញមានច្រើនជាងគេ ដោយសារតែការយល់ដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិត និងភាពធ្វេសប្រហែសរបស់ប្រជាពលរដ្ឋនៅមានច្រើននៅឡើយ។ ដូច្នេះរដ្ឋបាលក្រុងត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធនានា ដើម្បីធ្វើការចុះទៅបណ្តុះបណ្តាល និងណែនាំដល់ប្រជាពលរដ្ឋនៅមូលដ្ឋានឱ្យបានយល់ដឹងពីច្បាប់ចរាចរណ៍ តាមរយៈការពន្យល់ឱ្យបានយល់ច្បាស់ពីវិធាននៃចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ ស្លាកសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍ និងសីលធម៌ក្នុងពេលបើកបរ។
- **កត្តាផ្លូវ** ៖ ផ្លូវគឺជាផ្នែកមួយដែលចូលរួមចំណែកក្នុងការបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ និងការកកស្ទះចរាចរណ៍។ ដើម្បីឱ្យបញ្ហានេះអាចដោះស្រាយបាន អាជ្ញាធរពាក់ព័ន្ធត្រូវអនុវត្តដូចខាងក្រោម៖
    - o ត្រូវយកមកវិញនូវចិញ្ចើមផ្លូវ និងរក្សាចិញ្ចើមផ្លូវឱ្យបានសម្រាប់ទុកអ្នកថ្មើរជើងធ្វើដំណើរ
    - o ត្រូវមានរនាំងសុវត្ថិភាពនៅតាមចិញ្ចើមផ្លូវ ដើម្បីការងារសុវត្ថិភាពអ្នកថ្មើរជើង
    - o ត្រូវសាងសង់ស្ពានសម្រាប់អ្នកថ្មើរជើងដើរឆ្លងកាត់ផ្លូវ ដោយត្រូវសាងសង់នៅតំបន់ដូចជា មន្ទីរពេទ្យ សាលារៀន ផ្សារ រោងចក្រ និងតំបន់ដែលមានមនុស្សឆ្លងកាត់ច្រើន
    - o ហាមចតយានជំនិះគ្រប់ប្រភេទនៅលើផ្លូវសាធារណៈ ដែលបំពាននឹងច្បាប់ចរាចរណ៍ផ្លូវគោក
    - o មិនត្រូវអនុញ្ញាតឱ្យមានការលក់ដូរ ឬ ប្រកបអាជីវកម្មផ្សេងៗនៅលើចិញ្ចើមផ្លូវ
    - o ត្រូវជួសជុលផ្លូវណាដែលខូចខាត ទោះតិច ឬ ច្រើន និងត្រូវដាក់ស្លាកសញ្ញាសម្គាល់ និងភ្លើងសម្គាល់កន្លែងជួសជុលនោះ ជាដើម។

- **កត្តាយានជំនិះ** ៖ យានជំនិះគឺជាកត្តាចម្បងមួយដែរ ដែលបានចូលរួមបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍។ បញ្ហានេះបណ្តាលមកពីប្រជាពលរដ្ឋមួយចំនួននៅប្រើប្រាស់យានជំនិះចាស់ៗ ឬជជុសជាច្រើន ហើយយានជំនិះទាំងនោះមានពេលខ្លះកំពុងតែធ្វើដំណើរនៅលើផ្លូវស្រាប់តែមានបញ្ហាខូចត្រង់ចំណុចណាមួយជាយថាហេតុ ដែលជាហេតុអាចបណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍បានក្នុងពេលកំពុងធ្វើដំណើរ។ ដើម្បីដោះស្រាយបញ្ហានេះប្រជាពលរដ្ឋដែលជាម្ចាស់យានជំនិះទាំងអស់ ត្រូវតែទៅត្រួតពិនិត្យបច្ចេកទេសយានជំនិះរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងទៀងទាត់។

**គ.ការរៀបចំឱ្យមានចិញ្ចើមផ្លូវ**

ដើម្បីរៀបចំចិញ្ចើមផ្លូវឱ្យបានល្អ ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានគួរៈ

- ណែនាំ និងអនុវត្តឱ្យបានតឹងរឹងចំពោះអ្នកដែលបានយកចិញ្ចើមផ្លូវមកប្រើប្រាស់ជាកម្មសិទ្ធិផ្តាច់មុខ ដូចជា ដាក់រនាំងយកធ្វើជាកន្លែងធ្វើអាជីវកម្មលក់ដូរ ឬផ្ញើយានជំនិះផ្សេងៗ
- ណែនាំដល់ម្ចាស់ក្រុមហ៊ុននានា មិនត្រូវយកស្លាកយីហោរបស់ខ្លួនទៅដាក់តាំងនៅលើចិញ្ចើមផ្លូវសាធារណៈឡើយ
- ហាមចតយានជំនិះគ្រប់ប្រភេទនៅលើផ្លូវសាធារណៈ ដែលបំពាននឹងច្បាប់ចរាចរណ៍ផ្លូវគោក
- ហាមមិនឱ្យមានការសាងសង់សំណង់ផ្សេងៗដែលរំលោភលើចិញ្ចើមផ្លូវ
- ហាមឃាត់ការកាប់គាស់ និងជួសជុលចិញ្ចើមផ្លូវគ្មានសណ្តាប់ធ្នាប់
- ហាមឃាត់ការដាំដើមឈើគ្មានសណ្តាប់ធ្នាប់
- ការសាងសង់ចិញ្ចើមផ្លូវទាបខ្ពស់ៗ ដែលបង្កការលំបាកដល់អ្នកធ្វើដំណើរ។ល។

**២.១.១.២.ពេលយប់**

សោភ័ណភាពនាពេលរាត្រីជាកត្តាទាក់ទាញមួយយ៉ាងសំខាន់ ដែលអាជ្ញាធរពាក់ព័ន្ធត្រូវយកចិត្តទុកដាក់។ ដើម្បីទាក់ទាញប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងភ្ញៀវទេសចរដែលធ្វើដំណើរឆ្លងកាត់ទីរួមខេត្តឱ្យមកទស្សនា និងលេងកម្សាន្តនៅក្នុងក្រុងនាពេលរាត្រី អាជ្ញាធរក្រុងត្រូវរៀបចំការតុបតែង លម្អ និងបំពាក់ភ្លើងបំភ្លឺនៅតាមទីតាំងមួយចំនួនដូចខាងក្រោមៈ

- នៅតាមបណ្តាកន្លែងកម្សាន្តនានា ដូចជា សួនច្បារ កន្លែងហាត់ប្រាណ ជាដើម
- ផ្លូវ ស្ពាន ជុំវិញក្រុង
- សំណង់អគាររបស់ស្ថាប័ន អង្គភាពសាធារណៈ និងគ្រឹះស្ថានឯកជននៅក្នុងក្រុង។

**២.១.២.សណ្តាប់ធ្នាប់**

នាពេលបច្ចុប្បន្ននេះ ការរៀបចំសន្តិសុខ សណ្តាប់ធ្នាប់ក្នុងក្រុងច្បារមនត្រូវបានសាលាក្រុងយកចិត្តទុកដាក់យ៉ាងខ្លាំង តាមរយៈការខិតខំប្រឹងប្រែងធ្វើយ៉ាងណារក្សាឱ្យបាននូវសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋទាំងនៅក្នុងមូលដ្ឋានក្រុងផ្ទាល់ និងភ្ញៀវទេសចរដែលអញ្ជើញមកទស្សនាបានយ៉ាងល្អប្រសើរផងដែរ។ ទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងនេះក្តីក៏បញ្ហាសន្តិសុខ សណ្តាប់ធ្នាប់ក៏នៅតែមានបញ្ហាចោទមួយចំនួនផងដែរ ដោយសារតែការយល់ដឹងរបស់ប្រជាពលរដ្ឋមួយចំនួននៅមានកម្រិតដែលទាក់ទងទៅនឹងច្បាប់ និងបទប្បញ្ញត្តិមួយចំនួនទៀតដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីផ្លូវថ្នល់ ផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំមានសុវត្ថិភាព" ច្បាប់ និងបទដ្ឋានគតិយុត្តដែលអនុវត្តក្នុងវិស័យនគរូបនីយកម្ម និងសំណង់ជាដើម។ ទោះបីជាយ៉ាងនេះក្តីក៏អាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់នៅតែព្យាយាមរិះរកដំណោះស្រាយឱ្យទាន់សភាពការណ៍ និងដោយសន្តិវិធី ដើម្បីធ្វើយ៉ាងណាកាត់បន្ថយបញ្ហាទាំងអស់នោះបន្តិចម្តងៗ សំដៅធ្វើយ៉ាងណាប្រែក្លាយក្រុងច្បារមននេះឱ្យក្លាយជាក្រុងគំរូមួយដែលមានសណ្តាប់ធ្នាប់ល្អប្រសើរឡើងបន្ថែមទៀត។

**២.១.២.១.សន្តិសុខ**

**ក.សុវត្ថិភាពបុគ្គល**

ប្រជាពលរដ្ឋគ្រប់ៗរូបតែងតែចង់បាននូវសុវត្ថិភាពផ្ទាល់ខ្លួន។ ដើម្បីធានា និងការពារដល់សន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋបានអាជ្ញាធរពាក់ព័ន្ធត្រូវរៀបចំដូចខាងក្រោម៖

- **ចរាចរណ៍** ៖ អត្រាគ្រោះថ្នាក់ចរាចរណ៍នាពេលបច្ចុប្បន្ននេះមានការកើនឡើងជាលំដាប់ពីមួយថ្ងៃទៅមួយថ្ងៃ។ ដើម្បីកាត់បន្ថយបញ្ហានេះអាជ្ញាធរពាក់ព័ន្ធត្រូវណែនាំដល់ប្រជាពលរដ្ឋត្រូវ៖
    - o គោរពភ្លើងសញ្ញាចរាចរណ៍ គំនូសសញ្ញាចរាចរណ៍ និងស្លាកសញ្ញាចរាចរណ៍ឱ្យបានត្រឹមត្រូវ
    - o កុំបើកបរបញ្ច្រាសផ្លូវ
    - o កុំបើកបរលើផ្លូវអាទិភាពរបស់អ្នកដទៃ
    - o ហាមចតយានជំនិះគ្រប់ប្រភេទនៅលើផ្លូវសាធារណៈ ដែលបំពាននឹងច្បាប់ចរាចរណ៍ផ្លូវគោក
    - o ត្រូវចេះគោរព និងអធ្យាស្រ័យគ្នាទៅវិញទៅមក
    - o ហាមលក់ដូរលើចិញ្ចើមផ្លូវ

- o គួរប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ
- o មានសីលធម៌ក្នុងពេលបើកបរ ជាដើម។

- **ដើរហើរ** ៖ ប្រជាពលរដ្ឋគ្រប់ៗរូបតែងតែមានក្ដីបារម្ភចំពោះបញ្ហាសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន ដោយសារតែមានបញ្ហាមួយចំនួនដូចជាចោរកម្ម ឆក់ ប្លន់ បាញ់បោះ ក្មេងទំនើង។ល។ ដើម្បីចូលរួមកាត់បន្ថយបញ្ហានេះ អាជ្ញាធរពាក់ព័ន្ធត្រូវតែអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវគោលនយោបាយ "ភូមិ ឃុំមានសុវត្ថិភាព" ទាំង ០៩ចំណុច ជាពិសេសគឺត្រូវធ្វើយ៉ាងណាកាត់បន្ថយឱ្យបាននូវសកម្មភាពមួយចំនួនដូចខាងក្រោម៖
  - o គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ
  - o គ្មានក្មេងទំនើង
  - o គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ជាដើម។[១៩]

### ខ.សម្ភារ

សុវត្ថិភាពខាងផ្នែកសម្ភារក៏ជាផ្នែកមួយ ដែលត្រូវការអាជ្ញាធរពាក់ព័ន្ធយកចិត្តទុកដាក់ផងដែរ ព្រោះបើសិនជាបងប្អូនប្រជាពលរដ្ឋបាត់បង់សម្ភារច្រើនវាអាចនឹងបង្កជាក្ដីកង្វល់ដល់ពួកគាត់ ហើយអំពើនេះអាចបង្កជាភាពអសន្តិសុខដល់សង្គមផងដែរ។ កត្តាដែលនាំឱ្យមានសុវត្ថិភាពខាងផ្នែកសម្ភារ លុះត្រាតែក្នុងមូលដ្ឋាននោះ៖

- គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ
- គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរ ការចែកចាយ និងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- គ្មានក្មេងទំនើង
- គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ ជាដើម។

### គ.ចំណីអាហារ

ការត្រួតពិនិត្យចំណីអាហារ គឺជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) នៃក្រសួងពាណិជ្ជកម្ម ដែលមានសាខាកាំកុងត្រូលរាជធានី-ខេត្តជាសេនាធិការ។ សាខាកាំកុងត្រូលរាជធានី-ខេត្តមានភារកិច្ចដូចខាងក្រោម៖

[១៩] ផែនការណែនាំស្ដីពីការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំមានសុវត្ថិភាព", លេខ០២២ផក, ១០ សីហា ២០១២, ២ (ចាប់ពីពេលនេះតទៅហៅថាផែនការណែនាំលេខ០២២ផក)។

- ផ្តល់សេវាត្រួតពិនិត្យទំនិញនាំចេញ នាំចូលរួមជាមួយស្ថាប័នគយ និងរដ្ឋាករផ្អែកលើកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ
- ធ្វើវិញ្ញាបនបត្រចំពោះទំនិញនាំចេញ តាមសំណើរបស់អ្នកស្នើសុំ ដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃប្រទេសនាំចូល
- ត្រួតពិនិត្យភាពអនុលោមតាមស្តង់ដារជាតិនូវគុណភាព សុវត្ថិភាពផលិតផលទំនិញ ដែលមានប្រើសញ្ញាស្តង់ដារជាតិ
- សហការត្រួតពិនិត្យជាមុននូវប្រេតិវេទន៍ នៃផលិតផលទំនិញ ឬសេវាទាំងឡាយណា ដែលអាចប៉ះពាល់ដល់សុវត្ថិភាព សុខភាពនៃអ្នកប្រើប្រាស់ ឬផលិតកម្ម ឬពាណិជ្ជកម្ម នៃផលិតផល ទំនិញ និងសេវាកម្មទាំងនោះដែលផ្តល់ដោយស្ថាប័នមានសមត្ថកិច្ច
- ត្រួតពិនិត្យទំនិញផលិតផលទំនិញ និងសេវា ក្នុងដំណាក់កាលធ្វើចរាចរណ៍ពាណិជ្ជកម្មលើទីផ្សារ តាំងពិព័រណ៍ បង្ក្រាបការក្លែងបន្លំ និងប្រមូលកម្រៃសេវាត្រួតពិនិត្យទំនិញនាំចេញ-នាំចូល ដែលកំណត់ដោយប្រកាសរួមក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកដ្ឋានប្រគល់ឱ្យ។[២០]

### ២.១.២.២.ភាពស្ងប់ស្ងៀម

ដើម្បីឱ្យជីវិតរស់នៅបានក្តីសុខ មនុស្សភាគច្រើនតែងតែត្រូវការភាពស្ងប់ស្ងាត់។ ដូចនេះ អាជ្ញាធរពាក់ព័ន្ធមុននឹងរៀបចំប្លង់គោលនៃការអភិវឌ្ឍក្រុងត្រូវតែគិតលើបញ្ហានេះ ដោយត្រូវបែងចែកទីតាំងដែលអាចបង្កជាការរំខានដោយសំឡេងខ្លាំងៗ ដូចជា កន្លែងកម្សាន្ត ក្លឹប បារ ខារ៉ាអូខេ ភោជនីយដ្ឋាននានា ឱ្យនៅជាយក្រុង និងត្រូវណែនាំដល់ម្ចាស់ទីតាំងទាំងនោះឱ្យចេះរៀបចំប្រព័ន្ធកាត់បន្ថយសំឡេងឱ្យត្រូវតាមស្តង់ដារ និងបច្ចេកទេស។ ម្យ៉ាងវិញទៀត អាជ្ញាធរមូលដ្ឋានត្រូវតែចុះត្រួតពិនិត្យជាប្រចាំនូវរាល់កន្លែងកម្សាន្ត ក្លឹប បារ ខារ៉ាអូខេ ភោជនីយដ្ឋាននានា ដែលមាននៅក្នុងក្រុងជៀសវាងមានការបង្កការរំខានដោយសំឡេងណាមួយ ព្រមទាំងត្រូវណែនាំដល់ប្រជាពលរដ្ឋដែលមានកម្មវិធីនានា ដូចជា ពិធីរៀបអាពាហ៍ពិពាហ៍ ខួបកំណើត ជប់លៀងជាដើម ដោយមិនត្រូវមានការច្រៀងរាំដល់យប់ជ្រៅពេកនោះទេ ព្រោះវាអាចបង្កជាការរំខានដល់ប្រជាពលរដ្ឋដែលនៅជិតតំបន់នោះផងដែរ។

[២០] ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សាខាកាំកុងត្រូលរាជធានី-ខេត្ត, លេខ២៣៣៣.ណបល.ប្រក, ១៨ កក្កដា ២០១៦, ប្រការ១។

### ២.១.២.៣.អនាម័យ

នាពេលបច្ចុប្បន្ននេះ បញ្ហាបរិស្ថាននៅតែចោទជាបញ្ហានៅឡើយដោយក្នុងនោះវាបានបង្ក ជាបញ្ហានានាដែលបានផ្តល់ផលប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ និងរុក្ខជាតិយ៉ាងធ្ងន់ធ្ងរ ដែលទាមទារឱ្យមានការបង្កើនការយកចិត្តទុកដាក់ និងរៀបចំវាឡើងវិញ ដើម្បីធ្វើយ៉ាងណាដោះស្រាយបញ្ហានេះឱ្យបានល្អប្រសើរ។ ដើម្បីធ្វើឱ្យបរិស្ថានស្អាត លុះត្រាតែគ្មានការបំពុលទាំង ៥ ប្រភេទគឺៈ

#### ក.គ្មានការបំពុលទឹក

ទឹកមានមានសារៈសំខាន់ណាស់សម្រាប់ទ្រទ្រង់ជីវិតមនុស្ស សត្វ និងរុក្ខជាតិ។ ប៉ុន្តែការលេចចេញនូវឥទ្ធិពលអវិជ្ជមាន ទៅលើគុណភាពបរិស្ថាននៅក្នុងទឹកបានបង្កឱ្យមានផលវិបាកដល់ជីវិតមនុស្ស សត្វ ដោយសារការប៉ះពាល់សារធាតុគីមីរាប់ម៉ឺនប្រភេទរួមទាំងកាកសំណល់ដែលផ្ទុកជាតិពុលផ្សេងៗជាច្រើន តាមរយៈការបោះកាកសំណល់ លាមក ឬសំរាមទៅតាមប្រព័ន្ធលូទឹក និងតាមរូបភាពផ្សេងៗទៀត ជាហេតុបង្កឱ្យបរិស្ថានទឹកត្រូវបានបំពុល។

ទឹកកខ្វក់ សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វាក្រោយពីការប្រើប្រាស់រួមមានដូចជា ទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួមទាំងទឹកនោម និងលាមកដែលបញ្ចេញពីលំនៅដ្ឋាន បុរីលំនៅដ្ឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និងតំបន់ទីរមណីយដ្ឋាន ឬមជ្ឈមណ្ឌលកម្សាន្ត។ [២៧] ការបំពុលបរិស្ថានទឹកអាចជះឥទ្ធិពលអាក្រក់ដល់សោភ័ណភាពបរិស្ថានអាស្រ័យទៅតាមកម្រិតនៃការបំពុល ដែលភាគច្រើនមាននៅតាមទីកន្លែងសំខាន់ៗមួយចំនួនដូចជា រមណីយដ្ឋាន ទីក្រុង ទីប្រជុំជន ភូមិ ទីកម្សាន្ត ទីសាធារណៈជាដើម។

ប្រភពនៃការបំពុលបរិស្ថានទឹកអាចកើតឡើងតាមរយៈកត្តាមួយចំនួន ដូចខាងក្រោមៈ

- **កត្តាមនុស្ស** ៖ ទាក់ទងទៅនឹងមុខរបរអាជីវកម្មដែលប្រជាពលរដ្ឋប្រកបជារៀងរាល់ថ្ងៃ ដូចជា វិស័យឧស្សាហកម្ម វិស័យពាណិជ្ជកម្ម វិស័យសេវាកម្ម វិស័យកសិកម្ម ជាដើម ការប្រើប្រាស់ជីគីមីហួសកម្រិត និងមិនបានគ្រប់គ្រងឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដែលនាំឱ្យហូរធ្លាក់ចូលទៅក្នុងប្រភពទឹកដែលអាចបណ្តាលឱ្យបំពុលទឹក។ ការធ្វើដំណើរកម្សាន្តនៅតាមទូក កប៉ាល់ ឬ កាណូត អ្នកដំណើរខ្លះមិនបានរៀបចំទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ដែលជាហេតុធ្វើឱ្យកាកសំណល់ទាំងអស់នោះធ្លាក់ចូលទៅក្នុងទឹក។ បន្ថែមពីនេះ

[២៧] អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, លេខ២៣៥អនក្រ.បក, ២៥ ធ្នូ ២០១៧, មាត្រា៤ កថាខណ្ឌទី១ (ចាប់ពីពេលនេះតទៅហៅថាអនុក្រឹត្យលេខ២៣៥អនក្រ.បក)។

ទៀត ការបន្ទោបង់គ្មានសណ្ដាប់ធ្នាប់ ក៏ជាផ្នែកមួយដែលបណ្ដាលឱ្យមានការបំពុលបរិស្ថានទឹកបានដែរ។

- **កត្តាធម្មជាតិ** ៖ សារធាតុនីត្រូសែនមាននៅក្នុងទឹកភ្លៀង ហើយនៅពេលដែលទឹកភ្លៀងធ្លាក់ចូលក្នុងទឹកស្ទឹង ស្រះ ឬទន្លេ ក៏បានបំប្លែងទៅជាអាស៊ីតនីត្រាតដែលបង្កគ្រោះថ្នាក់ និងបំផ្លាញដល់ជីវិតរុក្ខជាតិ។

### ខ.គ្មានការបំពុលខ្យល់

ការបំពុលខ្យល់ គឺជាបញ្ហាមួយដែលបានកើតមានឡើងនៅក្នុងសម័យទំនើបនេះដោយសារតែការអភិវឌ្ឍយ៉ាងឆាប់រហ័សក្នុងតំបន់ជាច្រើន ដូចជា ឧស្សាហកម្ម ការដឹកជញ្ជូន វិស័យកសិកម្ម លំនៅដ្ឋាន រោងចក្រផលិតថាមពលកម្ដៅ ការប្រើប្រាស់ប្រេងឥន្ធនៈសម្រាប់ផលិតថាមពលឧស្សាហកម្ម និងការប្រើប្រាស់ប្រេងឥន្ធនៈជីវម៉ាសគឺជាកត្តាធំៗដែលរួមចំណែកនាំឱ្យមានការបំពុលខ្យល់។

ការបំពុលខ្យល់ កើតឡើងដោយសារធាតុគីមី ឬជីវៈសរីរាង្គដែលបំផ្លាញ ឬបណ្ដាលឱ្យមានផលប៉ះពាល់ដល់មនុស្ស ឬភាវៈមានជីវិតទាំងឡាយ និងបំផ្លាញដល់បរិស្ថានក្នុងបរិយាកាស។ បរិយាកាស គឺជាប្រព័ន្ធធម្មជាតិយ៉ាងរឹងមាំដែលទ្រទ្រង់រាល់ជីវិតមនុស្ស សត្វនានានៅលើផែនដី។ ការបំផ្លាញស្រទាប់អូហ្សូន គឺជាការបំផ្លាញរនាំងការពារផែនដីពីកាំរស្មីអ៊ុលត្រាវីយ៉ូលេដែលបង្កផលវិបាកដល់ជីវិតលើផែនដី។ ការបំពុលខ្យល់បានកំពុងជះឥទ្ធិពលជាអវិជ្ជមានជាច្រើនមកលើសុខភាពមនុស្ស សត្វ និងរុក្ខជាតិ ហើយពពួកសត្វ និងរុក្ខជាតិមួយចំនួនបានទទួលនូវការគំរាមកំហែង និងមួយចំនួនទៀតអាចឈានដល់ការផុតពូជ។ ម្យ៉ាងទៀតការសាយភាយនៃសារធាតុគីមីងាយធ្វើឱ្យមនុស្សចាស់ និងកុមាររងគ្រោះកើតជំងឺដែលបណ្ដាលមកការបំពុលហើយចំណែកឯអ្នកមានជំងឺបញ្ហាសួត ឬបេះដូងស្រាប់នោះអាចបណ្ដាលឱ្យសុខភាពកាន់តែធ្ងន់ធ្ងរទៅៗ ដោយសារតែការបំពុលខ្យល់នេះ។ មិនតែប៉ុណ្ណោះ ក៏មានជំងឺមួយចំនួនទៀតដែលបង្កឡើងដោយការបំពុលខ្យល់តែមិនមានបង្ហាញរោគសញ្ញា ជំងឺទាំងនោះមានដូចជា រលាកទងសួតរ៉ាំរ៉ៃ រោគ ហឺត មហារីក ជាដើម ដែលបណ្ដាលមកពីការស្រូបយកខ្យល់ដែលបានបំពុលនោះ។ មូលហេតុនៃការបំពុលខ្យល់មានដូចខាងក្រោម៖

- **សកម្មភាពឧស្សាហកម្ម ៖** នៅលើពិភពលោកនេះ មូលហេតុដ៏ធំមួយដែលនាំឱ្យមានការបំពុលបរិស្ថានក្នុងខ្យល់ខ្លាំង គឺបណ្ដាលមកពីកំណើននៃការប្រើប្រាស់វត្ថុធាតុដើមពីធម្មជាតិ និងអតុល្យភាពនៃប្រព័ន្ធអេកូឡូស៊ី។ សកម្មភាពឧស្សាហកម្មទាំងនេះបានបំភាយ

ផ្សែងពុល ឧស្ម័ន បញ្ចេញកាកសំណល់គ្រោះថ្នាក់ សំណល់ឧស្សាហកម្មនានាដែលមិនបាន គ្រប់គ្រងឱ្យបានត្រឹមត្រូវ។ល។

- **ការបោះចោលកាកសំណល់ ៖** សំណល់ផ្ទះបាយ និងសំណល់ពាណិជ្ជកម្មក៏បានបំពុល បរិស្ថានផងដែរ បើសិនជាយើងមិនបានទុកដាក់ និងគ្រប់គ្រងឱ្យបានត្រឹមត្រូវ ជាពិសេស ការកម្ទេចចោលសំរាម។ ភាគច្រើនគេសង្កេតឃើញ ការកម្ទេចចោលសំរាមមាន ២ ប្រភេទ គឺ ការដុតសំរាមចោល និងការកប់សំរាមចោល។
- **យានយន្ត ៖** ផ្សែងដែលចេញពីយានយន្តគ្រប់ប្រភេទ ជាពិសេសផ្សែងដែលចេញពីរថយន្ត ជជុស ជាដើម។
- **ការដុតឥន្ធនៈផូស៊ីល ៖** កំណើននៃការប្រើប្រាស់ឥន្ធនៈនៅក្នុងឧស្សាកម្មនានា។
- **សំណល់កសិកម្ម ៖** ការប្រើប្រាស់ថ្នាំគីមីកសិកម្ម និងថ្នាំសម្លាប់សត្វល្អិតហួសកម្រិត។

**គ.គ្មានការបំពុលដី**

ពីមួយឆ្នាំទៅមួយឆ្នាំ អត្រានៃការកើនឡើងនៃសំណល់សំរាមមានការកើនឡើងឥតឈប់ឈរជាលំដាប់ដែលវាបានបង្កផលប៉ះពាល់ដល់បរិស្ថាន ជាពិសេសគឺការប៉ះពាល់ដល់ការបំពុលដី។ អត្រានៃការកើនឡើងនេះបណ្ដាលមកពីអត្រាមនុស្សមានការកើតឡើង ហើយអត្រាតម្រូវការចេះតែកើនឡើងបន្ថែមទៀត ប៉ុន្តែការរៀបចំ គ្រប់គ្រង និងទុកដាក់សំរាមនៅមានកម្រិតនៅឡើយ។ នាពេលបច្ចុប្បន្ន មូលហេតុនៃការបំពុលដីជាទូទៅឃើញមានកត្តាចំនួន ៣ គឺ៖

- **កត្តាមនុស្ស ៖** វាជាកត្តាចម្បងមួយនៃការបំពុលដី ដោយសារតែមនុស្សមួយចំនួនពុំបាន គ្រប់គ្រង និងទុកដាក់សំរាមឱ្យបានត្រឹមត្រូវ ដែលជាហេតុធ្វើឱ្យសំរាមនៅរាយប៉ាយនៅដី ហើយមួយចំនួនទៀតបានកម្ទេចសំរាមដោយយកទៅដុត ឬកប់ចោលក្នុងដី ជាដើម។
- **កត្តាឧស្សាហកម្ម ៖** កត្តានេះដែរភាគច្រើនគឺពាក់ព័ន្ធទៅនឹងរោងចក្រ ដែលបង្ហូរទឹកស្អុយទៅលើដី ឬទឹកដែលបង្កឱ្យមានការបំពុល ជាពិសេសឧស្សាហកម្មធន់ធ្ងន់ជាច្រើន ដូចជា រោងចក្រផលិតសារជាតិគីមីលោហៈធាតុ និងក្រដាសជាដើម ផលិតផលទាំងអស់នេះ គឺសុទ្ធតែប៉ះពាល់ទៅដល់បរិស្ថាន។
- **កត្តាកសិកម្ម ៖** ក្នុងវិស័យកសិកម្ម ភាគច្រើនទាក់ទងនឹងការប្រើប្រាស់ថ្នាំគីមីកសិកម្ម និងថ្នាំសម្លាប់សត្វល្អិតហួសកម្រិត។

**ឃ.គ្មានការបំពុលដោយសំណល់រឹងរាវ**

ជារៀងរាល់ថ្ងៃ គឺមានសំរាមជាច្រើនដែលត្រូវបានបោះចោល ទោះបីជាសំរាមទាំងនោះជាប្រភេទណាក៏ដោយ បើសិនជាពុំចេះរៀបចំទុកដាក់សំរាមទាំងនោះឱ្យបានល្អទេ វាអាចធ្វើឱ្យ

បណ្តាលឱ្យមានមេរោគផ្សេងៗ ជាហេតុធ្វើឱ្យប៉ះពាល់ដល់ជីវិតមនុស្ស សត្វ និងរុក្ខជាតិ ព្រមទាំងអាចបណ្តាលឱ្យមានការកកស្ទះប្រព័ន្ធលូរំដោះទឹកផងដែរ។ ការបំពុលដោយសំណល់ត្រូវបានគេបែងចែកជា ២ ប្រភេទគឺ៖

- **សំណល់រឹង** ៖ គឺសំដៅដល់វត្ថុរឹង សារធាតុរឹង ឬ វត្ថុកម្ទេចកម្ទីដែលគេលែងត្រូវការប្រើប្រាស់ បោះបង់ចោល ឬ តម្រូវឱ្យបោះបង់ចោល។[២២] ជាទូទៅបញ្ហានៃការញែក ការវេចខ្ចប់ ការទុកដាក់សំរាម និងការបញ្ចេញសំរាមសំណល់រឹងភាគច្រើនមាននៅតាមបណ្តាទីប្រជុំជននានា។ ហេតុនេះហើយ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំដីកា ឬ លិខិតបទដ្ឋាននានា ដើម្បីណែនាំអនុវត្តការសម្អាត ការញែក ការវេចខ្ចប់ ការទុកដាក់ និងការបញ្ចេញសំរាមសំណង់រឹងទីប្រជុំជន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃទីប្រជុំជននីមួយៗ និងត្រូវធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន និងលើកកម្ពស់សោភ័ណភាព អនាម័យ និងបរិស្ថាននៅតាមទីប្រជុំជន។[២៣] បន្ថែមពីនេះទៀត ម្ចាស់សំរាមសំណល់រឹងទីប្រជុំជនត្រូវ៖
    - o អនុវត្តការញែក និងការវេចខ្ចប់សំរាមសំណល់រឹង ដែលអាចប្រើប្រាស់ឡើងវិញ ឬ កែច្នៃបានដាច់ដោយឡែកពីសំរាមសំណល់រឹង ដែលត្រូវបោះចោលទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។[២៤]
    - o ត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ដោយថង់ ឬការដាក់នៅក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំរាមសំណល់រឹងទីប្រជុំជន ដែលបានបង្កើតក្នុងលក្ខណៈហ្មត់ចត់មិនឱ្យលេចធ្លាយ មិនឱ្យលេចជ្រាបទឹកស្អុយ ឬ មិនឱ្យមានភាយក្លិនស្អុយក្នុងរយៈពេលនៃការទុកដាក់រង់ចាំការបញ្ចេញទៅតាមការណែនាំរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។[២៥]
    - o ត្រូវទទួលខុសត្រូវក្នុងការរក្សាទុកនូវកញ្ចប់ ឬ ធុងផ្ទុកសំរាមសំណល់រឹងរបស់ខ្លួននៅក្នុងរបង ឬ បរិវេណនៃលំនៅដ្ឋាន អគារ ឬ ទីតាំងរបស់ខ្លួន និងត្រូវបញ្ចេញទៅតាមពេលម៉ោងដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។ រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវចាត់វិធានការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់លើការអនុវត្តការ

---

[២២] គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com (ថតចម្លងថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨)។

[២៣] អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ១១៣អនក្រ.បក, ២៧ សីហា ២០១៥, មាត្រា១៩ កថាខណ្ឌទី១ (ចាប់ពីពេលនេះតទៅហៅថាអនុក្រឹត្យលេខ១១៣អនក្រ.បក)។

[២៤] អនុក្រឹត្យលេខ១១៣អនក្រ.បក, មាត្រា១៥។

[២៥] អនុក្រឹត្យលេខ១១៣អនក្រ.បក, មាត្រា១៦។

បញ្ចេញកញ្ចប់ ឬ ធុងផ្ទុកសំរាមសំណល់រឹងទីប្រជុំជនទៅដាក់នៅតាមដងផ្លូវ ឬ ទីសាធារណៈរង់ចាំការប្រមូល និងដឹកជញ្ជូនទៅតាមពេលម៉ោងដែលបានកំណត់។[២៦]

o ម្ចាស់សំរាមសំណល់រឹងទីប្រជុំជន ដែលប្រើប្រាស់សេវាគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជនត្រូវបង់ថ្លៃសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជនដែលកំណត់ដោយរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌ។[២៧]

- **សំណល់រាវ** ៖ សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថាន ដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬ សេវាកម្ម។[២៨] ចំពោះប្រភេទសំណល់រាវខ្លះត្រូវបានស្ថាប័នពាក់ព័ន្ធឱ្យបញ្ចេញពីអគារអាជីវកម្ម បុរីលំនៅដ្ឋាន ទីក្រុងរណប និងតំបន់រមណីយដ្ឋាន ឬ មណ្ឌលកម្សាន្តចូលទៅក្នុងប្រព័ន្ធលូដែលភ្ជាប់ទៅស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួមមុនពេលបង្ហូរទៅកាន់ប្រភពទឹកនានា និងប្រភេទសំណល់រាវខ្លះទៀតអាចបង្ហូរចូលទៅក្នុងទឹកសាធារណៈ (សំដៅដល់ប្រភពទឹកសម្រាប់ប្រើប្រាស់ជាសាធារណៈ ដូចជាទន្លេ ដៃទន្លេ ស្ទឹង ព្រែក អូរ បឹង ស្រះ ត្រពាំង សមុទ្រ ដៃសមុទ្រ ពាម ប្រព័ន្ធប្រឡាយធារាសាស្ត្រ ទឹកក្រោមដី។ល។) ដោយផ្ទាល់ ឬ ឆ្លងកាត់តាមប្រព័ន្ធលូ។[២៩]

### ង.គ្មានការបំពុលដោយសំឡេង

ចំពោះប្រទេសកម្ពុជា ការបំពុលដោយសំឡេងមានតិចតួចបំផុតដោយសារតែប្រជាពលរដ្ឋមួយចំនួនធំមានការយល់ដឹងច្រើនលើបញ្ហានេះ ប៉ុន្តែក៏មានការបំពុលដោយសំឡេងមួយចំនួនដែលប្រទេសកម្ពុជាកំពុងជួបប្រទះដែរដូចជា ក្លឹបខារ៉ាអូខេ រោងចក្រ ការកែច្នៃបច្ចេកទេសសំឡេងនៅលើរថយន្ត ម៉ូតូពុំត្រឹមត្រូវតាមស្តង់ដារបច្ចេកទេស ការដ្ឋានសាងសង់នានាជាដើម ដែលសំឡេងទាំងអស់នេះបានបង្កជាការរំញ័រ និងការរំខាន ហើយអាចប៉ះពាល់អ្នកប្រជាពលរដ្ឋដែលរស់នៅជិតតំបន់ទាំងនោះបាន។ ប្រភពនៃការបំពុលដោយសំឡេងត្រូវបានបែងចែកជា ០២ គឺ៖

- **ប្រភពចល័ត** ៖ គឺជាប្រភពដែលស្ថិតនៅទីតាំងមិនអចិន្ត្រៃយ៍ជាអាទ៍មាន យន្តហោះ នាវាដឹកជញ្ជូន យានយន្ត គ្រឿងយន្ត និងគ្រឿងបំពងសំឡេងគ្រប់ប្រភេទ។

---

[២៦] អនុក្រឹត្យលេខ១១៣អនក្រ.បក, មាត្រា១៧។

[២៧] អនុក្រឹត្យលេខ១១៣អនក្រ.បក, មាត្រា១៨។

[២៨] អនុក្រឹត្យលេខ២៣៥អនក្រ.បក, មាត្រា៤ កថាខណ្ឌទី២។

[២៩] អនុក្រឹត្យលេខ២៣៥អនក្រ.បក, តារាងឧបម្ព័ន្ធទី១ និងទី២។

- **ប្រភពអចល័ត** ៖ គឺជាប្រភពដែលស្ថិតនៅទីតាំងអចិន្ត្រៃយ៍មួយកន្លែងជាអាទិ៍មាន រោងចក្រ សហគ្រាស ឃ្លាំងស្តុកសម្ភារ ការដ្ឋានសំណង់ ឡដុតសំរាម គ្រឿងបំពងសំឡេង សិប្បកម្ម និងកសិដ្ឋានគ្រប់ប្រភេទ។[៣០]

មកទល់ពេល មានការកម្រិតកំណត់ស្តង់ដារបញ្ចេញសំឡេងពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកម្រិតកំណត់ស្តង់ដារសំឡេងអតិបរមាសម្រាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋាន។[៣១] ម្យ៉ាងវិញទៀតក៏មានការហាមឃាត់ដាច់ខាតនូវការបង្កឱ្យមានសំឡេងមួយចំនួន ដែលមិនឆ្លើយតបទៅនឹងកម្រិតកំណត់ស្តង់ដារសំឡេងផងដែរ។[៣២]

## ២.២.បញ្ហាក្នុងការអភិវឌ្ឍក្រុង

### ២.២.១.បញ្ហាប្រឈម

- ពុំទាន់មានប្លង់គោលក្នុងការអភិវឌ្ឍក្រុង ដែលជាហេតុនាំឱ្យពិបាកក្នុងការកំណត់ និងបែងចែកតំបន់ដែលត្រូវអភិវឌ្ឍ ដោយសារខ្វះអ្នកបច្ចេកទេស និងថវិកា
- ការសាងសង់សំណង់មួយចំនួនពុំទាន់គោរពតាមច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងការសាងសង់
- ការចតយានជំនិះគ្មានសណ្តាប់ធ្នាប់ ដែលជាហេតុនាំឱ្យមានការកកស្ទះនៅតាមតំបន់មួយចំនួន
- វិស័យគមនាគមន៍ខ្លះ មិនទាន់មានថវិកាក្នុងការជួសជុល ថែទាំផ្លូវ ស្ពាន ដែលប្រើប្រាស់ជាច្រើនឆ្នាំមកហើយនៅមានសភាពចាស់ទ្រុឌទ្រោម និងការគ្រប់គ្រងមិនបានដិតដល់ចំពោះរថយន្តមួយចំនួនដែលធ្វើការដឹកជញ្ជូនលើសទម្ងន់
- ការរៀបចំឱ្យមានចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរជើងនៅមានកម្រិតតិចតួចនៅឡើយ
- ការរៀបចំតុបតែងភ្លើងនៅតាមស្ថាប័ន អង្គភាពសាធារណៈ និងឯកជនក្នុងខេត្តនៅមានកម្រិត
- ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងការគោរពច្បាប់ចរាចរណ៍នៅមានកម្រិត
- ការគ្រប់គ្រងកាកសំណល់នៅមានកម្រិត
- ការបំពុលខ្យល់តិចតួច តាមរយៈការមិនសម្អាតដីនៅតាមខឿនពុះចែកទ្រូងផ្លូវ។

---

[៣០] អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ៤២អនក្រ.បក, ១០ កក្កដា ២០០០, មាត្រា៣ (ចាប់ពីពេលនេះតទៅហៅថាអនុក្រឹត្យលេខ៤២អនក្រ.បក)។

[៣១] អនុក្រឹត្យលេខ៤២អនក្រ.បក, មាត្រា៧។

[៣២] អនុក្រឹត្យលេខ៤២អនក្រ.បក, មាត្រា៩។

### ២.២.២.ដំណោះស្រាយ

- **ពុំទាន់មានប្លង់គោលក្នុងការអភិវឌ្ឍក្រុង ដែលជាហេតុនាំឱ្យពិបាកក្នុងការកំណត់ និងបែងចែកតំបន់ដែលត្រូវអភិវឌ្ឍ ដោយសារខ្វះអ្នកបច្ចេកទេស និងថវិកា ៖** មកទល់ពេលបច្ចុប្បន្ននេះ ទោះបីជាក្រុមច្បាប់មនពុំទាន់មានប្លង់គោលសម្រាប់រៀបចំការអភិវឌ្ឍក្ដី ក៏ប៉ុន្តែអាជ្ញាធរពាក់ព័ន្ធទាំងអស់ នៅតែខិតខំប្រឹងប្រែងសុំកិច្ចសហការពីមន្ទីរជំនាញពាក់ព័ន្ធនានាជុំវិញខេត្ត ដើម្បីធ្វើយ៉ាងណារៀបចំជាផែនការនានាក្នុងការរៀបចំអភិវឌ្ឍជាជំហានៗ ដោយផ្ដល់ឱកាសផ្ទាល់ពីការិយាល័យជុំវិញក្រុង ការិយាល័យចំណុះសាលាក្រុង ក្រុមប្រឹក្សាសង្កាត់ អង្គការសង្គមស៊ីវិល វិស័យឯកជន ប្រជាពលរដ្ឋ នៅក្នុងដំណើរការរៀបចំ និងកសាងផែនការណ៍នេះឡើង។
- **ការសាងសង់សំណង់មួយចំនួនពុំទាន់គោរពតាមច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងការសាងសង់ ៖** ក្នុងនោះយើងសង្កេតឃើញមានការសាងសង់អគារ កន្លែងសម្រាប់លក់ដូរ ការដាក់តាំងប៉ាណូពាណិជ្ជកម្មនានា ដោយបានរំលោភបំពានលើផ្លូវសាធារណៈដោយគ្មានសណ្ដាប់ធ្នាប់ និងមានភាពរញ៉េរញ៉ៃ។ ចំពោះបញ្ហានេះអាជ្ញាធរក្រុងបានសុំកិច្ចសហការពីការិយាល័យរៀបចំក្រុង អង្គភាពពាក់ព័ន្ធ ដើម្បីចុះហាមឃាត់សំណង់ដែលខុសច្បាប់នានាជុំវិញខេត្ត និងចុះរៀបចំសណ្ដាប់ធ្នាប់នៅតាមទីតាំងមួយចំនួនក្នុងក្រុងផងដែរ ប៉ុន្តែនៅមានមួយចំនួនទៀត បន្ទាប់ពីអាជ្ញាធរចុះរុះរើហើយពួកគាត់នៅតែលួចសាងសង់ដោយរំលោភផ្លូវសាធារណៈ។ ទន្ទឹមនឹងនេះដែរ អាជ្ញាធរនៅតែបង្កើនការចុះអប់រំណែនាំ និងចេញសេចក្ដីជូនដំណឹងដល់ប្រជាពលរដ្ឋ ធ្វើយ៉ាងណាកុំឱ្យពួកគាត់យកផ្លូវសាធារណៈមកប្រើប្រាស់ផ្ដាច់មុខ ដូចជា នៅតាមបរិវេណវិមានឯករាជ្យ សួនច្បារនានាក្នុងក្រុង ដែលវាអាចបណ្ដាលឱ្យមានការកកស្ទះចរាចរណ៍ ឬ គ្រោះថ្នាក់នានាជាយថាហេតុផងដែរ។[៣៣]
- **ការចតយានជំនិះគ្មានសណ្ដាប់ធ្នាប់ ដែលជាហេតុនាំឱ្យមានការកកស្ទះនៅតាមតំបន់មួយចំនួន ៖** ការចតយានជំនិះគ្មានសណ្ដាប់ធ្នាប់ភាគច្រើនគេសង្កេតឃើញមាននៅជុំវិញផ្សារកំពង់ស្ពឺ។ ដើម្បីដោះស្រាយបញ្ហានេះ អាជ្ញាធរមានចុះធ្វើការណែនាំដល់ប្រជាពលរដ្ឋមិនឱ្យ

[៣៣] សេចក្ដីជូនដំណឹងស្ដីពីការបញ្ឈប់ការលក់ដូរអនាធិបតេយ្យតាមចិញ្ចើមផ្លូវជុំវិញរបងសាលាខេត្ត ជុំវិញបរិវេណវិមានឯករាជ្យ និងជុំវិញសួនច្បារខាងលិច និងខាងកើត, លេខ២១៣/១៧សជណ, ១៨ តុលា ២០១៧។

ចតឡាននៅលើផ្លូវសាធារណៈ ឬ សួនច្បារឡើយ ជាពិសេសគឺបានចុះរៀបចំសណ្តាប់ធ្នាប់នៅបរិវេណផ្សារកំពង់ស្ពឺ និងបេនឡានជាដើម។[៣៤]

- **វិស័យគមនាគមន៍ខ្លះ៖ មិនទាន់មានថវិកាក្នុងការជួសជុល ថែទាំផ្លូវ ស្ពាន ដែលប្រើប្រាស់ជាច្រើនឆ្នាំមកហើយនៅមានសភាពចាស់ទ្រុឌទ្រោម និងការគ្រប់គ្រងមិនបានជិតដល់ចំពោះរថយន្តមួយចំនួនដែលធ្វើការដឹកជញ្ជូនលើសទម្ងន់** ៖ ដើម្បីដោះស្រាយបញ្ហានេះអាជ្ញាធរក្រុងក៏ដូចជាមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តបានរៀបចំផែនការសម្រាប់ការជួសជុលផ្លូវការងារថែទាំផ្លូវថ្នល់ជាប្រចាំ (ផ្លូវក្រាលកៅស៊ូ) ជាដើម។[៣៥] បន្ថែមពីនេះអាជ្ញាធរក្រុងក៏បានដឹកនាំប្រជុំគណៈបញ្ជាការឯកភាពក្រុង ស្តីពីការចុះត្រួតពិនិត្យអនុវត្តបញ្ហារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាស្តីពីរថយន្តកែច្នៃទ្រង់ខុសលក្ខណៈបច្ចេកទេសនៅទីតាំងមួយចំនួនក្នុងក្រុងផងដែរ។[៣៦]
- **ការរៀបចំឱ្យមានចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរជើងនៅមានកម្រិតតិចតួចនៅឡើយ** ៖ បច្ចុប្បន្នការរៀបចំឱ្យមានចិញ្ចើមផ្លូវសម្រាប់អ្នកថ្មើរនៅមានចំនួនតិចតួចនៅឡើយ ក៏ប៉ុន្តែអាជ្ញាធរមានគម្រោងបង្កើតឱ្យមានស្ពានសម្រាប់អ្នកដំណើរថ្មើរជើង (SKYWALK) ចំនួន ០២ កន្លែង ទី១ ត្រង់ចំណុចបេនឡានផ្សារកំពង់ស្ពឺ និងទី២ ត្រង់ចំណុចមុខសាលាបឋមសិក្សាសន្តិភាព។ ការកសាងស្ពានសម្រាប់អ្នកដំណើរថ្មើរជើង (SKYWALK) ទាំងពីរកន្លែងនេះដើម្បីជួយសម្រួលក្នុងការឆ្លងថ្នល់របស់ប្រជាពលរដ្ឋ សិស្សានុសិស្ស ព្រមទាំងជួយកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ជាយថាហេតុ ការកាត់បន្ថយការកកស្ទះចរាចរណ៍ និងចូលរួមលើកកម្ពស់សោភ័ណភាពខេត្តទាំងមូលផងដែរ។[៣៧]
- **ការរៀបចំតុបតែងភ្លើងនៅតាមស្ថាប័ន អង្គភាពសាធារណៈ និងឯកជនក្នុងខេត្តនៅមានកម្រិត** ៖ អាជ្ញាធរក្រុងបានស្នើសុំឱ្យស្ថាប័ន អង្គភាពសាធារណៈ និងឯកជនក្នុងខេត្តទាំងអស់ជួយរៀបចំតុបតែងលម្អស្ថាប័នរបស់ខ្លួន ព្រមទាំងបង្កើនឱ្យមានការរៀបចំតុបតែងភ្លើងបន្ថែមទៀតនៅតាមទីតាំងនានា ដូចជា សួនច្បារ កន្លែងកម្សាន្តនានាផងដែរ។

[៣៤] សាលាក្រុងច្បារមន, *របាយការណ៍ត្រីមាសទី១ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងច្បារមន*, លេខ០៩/១៨រ.ប.ក (កំពង់ស្ពឺ៖ សាលាក្រុងច្បារមន, ២៣ មីនា ២០១៧), ៥។

[៣៥] ធាតុចូលពីមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត ឆ្នាំ២០១៨-២០២១។

[៣៦] សាលាក្រុងច្បារមន, *របាយការណ៍ត្រីមាសទី១ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងច្បារមន*, លេខ០៩/១៨រ.ប.ក (កំពង់ស្ពឺ៖ សាលាក្រុងច្បារមន, ២៣ មីនា ២០១៧), ៤។

[៣៧] គណនី Facebook របស់រដ្ឋបាលខេត្តកំពង់ស្ពឺ www.facebook.com/រដ្ឋបាលខេត្តកំពង់ស្ពឺ (ថតចម្លងថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨)។

- **ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងការគោរពច្បាប់ចរាចរណ៍នៅមានកម្រិត** ៖ អាជ្ញាធរមូលដ្ឋានបានចុះអប់រំណែនាំដល់ប្រជាពលរដ្ឋ នៅតាមមូលដ្ឋាននានាក្នុងក្រុងអំពីច្បាប់ចរាចរណ៍ និងបានចុះចែកមួកការពារសុវត្ថិភាពជូនប្រជាពលរដ្ឋផងដែរ។[៣៨]
- **ការគ្រប់គ្រងកាកសំណល់នៅមានកម្រិត** ៖ អាជ្ញាធរបានចុះអប់រំណែនាំដល់ប្រជាពលរដ្ឋឱ្យចេះញែកសំរាម ការវេចខ្ចប់ និងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវនៅតាមមូលដ្ឋាននានាជុំវិញក្រុង ជាពិសេសអាជ្ញាធរក៏បានចេញសេចក្តីណែនាំស្តីពីការចូលរួមប្រារព្ធទិវាអនាម័យបរិស្ថានជាតិ ២៣ វិច្ឆិកា ដោយសំណូមពរដល់មន្ទីរ អង្គភាព គ្រឹះស្ថានសាធារណៈ ក្រុមហ៊ុនសហគ្រាស រោងចក្រនានាឱ្យចូលរួមសម្អាតអនាម័យបរិស្ថានទាំងក្នុង និងក្រៅបរិវេណអង្គភាពរៀងៗខ្លួន ហើយប្រមូលទុកដាក់ និងវេចខ្ចប់សំរាម សំណល់រឹងឱ្យបានត្រឹមត្រូវ ដោយមិនត្រូវដុតសំរាម ឬបោះចោលពាសវាលពាសកាលឡើយ ព្រោះវាអាចបណ្តាឱ្យមានការបំពុលដី ការបំពុលខ្យល់។ល។ បន្ថែមពីនេះ ចំពោះក្រុមហ៊ុនម៉ៅការដឹកជញ្ជូនសំរាមក្រុងស្រុក ត្រូវមានផែនការប្រមូល ដឹកជញ្ជូនសំណល់សំរាមឱ្យបានទាន់ពេលវេលា និងស្របតាមលក្ខណៈបច្ចេកទេស ដោយយកទៅចាក់ចោលដល់ទីលានចាក់សំរាម និងមិនបន្សល់ទុកគំនរសំរាមតាមដងផ្លូវ និងទីសាធារណៈឡើយ។[៣៩]
- **ការបំពុលខ្យល់តិចតួច តាមរយៈការមិនសម្អាតដីនៅតាមខឿនពុះចែកទ្រូងផ្លូវ** ៖ នៅតាមខឿនពុះចែកទ្រូងផ្លូវចាប់ពីកំណាត់ផ្លូវចូលឃោធភូមិភាគទី៣ រហូតដល់សាលាបឋមសិក្សាប៊ុន រ៉ានី ហ៊ុន សែន អង្គសិរី មានធូលីដីជាច្រើននៅតាមដងផ្លូវដែលបង្កមានខ្យល់មិនសូវបរិសុទ្ធ ដែលបានបណ្តាលឱ្យអ្នកធ្វើដំណើរពិបាកដកដង្ហើម ហុយដី ជាដើម។ បញ្ហាខាងលើនេះដែរត្រូវបានអាជ្ញាធរពាក់ព័ន្ធបានយកចិត្តទុកដាក់ ដោយមានការសហការជាមួយកងកម្លាំងប្រដាប់អាវុធ មន្ទីរ អង្គភាព មន្ត្រីរាជការ សិស្សានុសិស្ស និងស្ថាប័នឯកជននានាជាពិសេសគឺ ក្រុមហ៊ុន ខ្មែរ ប៊ែវើរីជីស ដែលបានយករថយន្តសម្អាតធុនធ្ងន់ចំនួន ០២គ្រឿងដើម្បីយកមកសម្អាតផ្លូវក្នុងខេត្តកំពង់ស្ពឺ ដែលឆ្លើយតបតាមការសំណូមពររបស់ខេត្តក្នុងកិច្ចការបរិស្ថាន និងជួយបង្កើននូវសោភ័ណភាពក្នុងខេត្តថែមមួយកម្រិតទៀតផងដែរ។[៤០]

[៣៨] សាលាក្រុងច្បារមន, *របាយការណ៍ត្រីមាសទី១ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងច្បារមន*, លេខ០៩/១៨រ.ប.ក (កំពង់ស្ពឺ៖ សាលាក្រុងច្បារមន, ២៣ មីនា ២០១៧), ៩។

[៣៩] សេចក្តីណែនាំស្តីពីការចូលរួមប្រារព្ធទិវាអនាម័យបរិស្ថានជាតិ ២៣ វិច្ឆិកា, លេខ០៥/១៧សណន, ១៥ វិច្ឆិកា ២០១៧។

[៤០] គណនី Facebook របស់រដ្ឋបាលខេត្តកំពង់ស្ពឺ www.facebook.com/រដ្ឋបាលខេត្តកំពង់ស្ពឺ (ថតចម្លងថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨)

# សេចក្ដីសន្និដ្ឋាន

យោងតាមការបកស្រាយខាងលើ យើងសង្កេតឃើញថា ដើម្បីអាចរៀបចំក្រុងមួយឱ្យមានសោភ័ណភាព និងសណ្ដាប់ធ្នាប់ អាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធត្រូវតែបំពេញកិច្ចការងារជាច្រើន ជាពិសេសគឺត្រូវរៀបចំឱ្យមានប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ជាមុន ព្រោះថាប្លង់គោលជាឯកសារមួយដែលមិនអាចខ្វះបានវិស័យនគរូបនីយកម្ម ដែលប្រៀបបានជាច្បាប់មួយដែលរាល់សំណង់ទាំងអស់មុនត្រូវបានអនុញ្ញាតសាងសង់ត្រូវតែគោរពតាមប្លង់នេះជាដាច់ខាត បើមិនដូច្នេះទេសំណង់ទាំងនោះមិនត្រូវបានអនុញ្ញាតឱ្យសាងសង់ឡើយ ហើយបើនៅតែសាងសង់ទៀត នោះម្ចាស់សំណង់នឹងត្រូវទទួលរងនូវទណ្ឌកម្មនានាជាក់ជាមិនខាន។ ចំពោះប្លង់ប្រើប្រាស់ដីធ្លី និងសំណង់វិញ ក៏មានសារៈសំខាន់ដែរ ព្រោះថាប្លង់នេះបានកំណត់យ៉ាងច្បាស់អំពីតំបន់ដែលត្រូវប្រើប្រាស់សម្រាប់ការពារជាតិ សម្រាប់កសិកម្ម សម្រាប់ពាណិជ្ជកម្ម សម្រាប់ឧស្សាហកម្ម សិប្បកម្ម វប្បធម៌ ទេសចរណ៍ សាសនា ព្រមទាំងសម្រាប់សំណង់នៃរដ្ឋបាល និងបរិក្ខារសាធារណៈ។ ម្យ៉ាងវិញទៀតប្លង់នេះកំណត់ផងដែរនូវលទ្ធភាពសម្រាប់សាងសង់ ព្រមទាំងត្រូវគោរពតាមប្លង់គោល។[៧]

សរុបសេចក្ដីមកយើងអាចសន្និដ្ឋានបានថា ទោះបីជាក្រុងច្បារមននាពេលបច្ចុប្បន្នពុំទាន់មានការរៀបចំឱ្យមានប្លង់គោល ដោយសារតែថវិកាដែលបានផ្ដល់ពីថ្នាក់លើមានចំនួនតិចតួច និងពុំសូវមានអ្នកជំនាញក៏ពិតមែន ក៏ប៉ុន្តែអាជ្ញាធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនៅតែខិតខំរៀបចំផែនការនៃការរៀបចំអភិវឌ្ឍក្រុងជាជំហានៗ តាមរយៈការរៀបចំផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ (២០១៥-២០១៩) និងកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៨-២០២០) ដើម្បីធ្វើយ៉ាងណាប្រែក្លាយក្រុងដ៏ស្ងប់ស្ងាត់មួយនេះឱ្យកាន់តែមានភាពរីកចម្រើនបន្ថែមទៀត ជាពិសេសគឺការខិតខំប្រឹងប្រែងរៀបចំក្រុងមួយនេះឱ្យកាន់តែមានសោភ័ណភាព និងសណ្ដាប់ធ្នាប់ តាមរយៈការចូលរួមប្រឡងប្រណាំងទីក្រុងស្អាតជាដើម (ក្រុងច្បារមនបានទទួលបានជ័យលាភីឡាបែល "ផ្កាដួងមួយទង" ក្នុងឆ្នាំ២០១៥-២០១៨ និងបានទទួលបានជ័យលាភីឡាបែល "ផ្កាដួងមួយទង" ក្នុងឆ្នាំ២០១៨-២០២១)។

[៧] ច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់, គ្មានលេខ, ២៤ ឧសភា ១៩៩៤, មាត្រា៧-៨។

# អនុសាសន៍

យោងតាមការចុះទៅពិនិត្យមើលពីស្ថានភាពជាក់ស្តែងនៅក្នុងក្រុងច្បារមន យើងខ្ញុំសង្កេតឃើញថាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយក្នុងនោះរួមមាន សួនច្បារតាមបណ្តោយស្ទឹងព្រែកត្នោត វិមានតម្កល់រូបសំណាកសម្តេចព្រះសង្ឃរាជជួនណាតជោតញ្ញាណោ វិមានឯករាជ្យផ្សារពាត្រី កន្លែងហាត់ប្រាណ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត ដែលត្រូវបានរៀបចំកែលម្អដោយមានការតុបតែងភ្លើងពណ៌នាពេលរាត្រី អមទៅដោយការបាញ់ទឹកនៅកណ្តាលស្ទឹង និងសួនច្បារយ៉ាងស្អាត ដែលបានទាក់ទាញប្រជាពលរដ្ឋដែលរស់នៅទីនោះ ក៏ដូចជាភ្ញៀវទេសចរណ៍ឱ្យចូលមកទស្សនា និងលេងកម្សាន្ត។ ទោះបីជាយ៉ាងនេះក្តីក៏មានបញ្ហាមួយចំនួនទៀតដែលអាជ្ញាធរក្រុងបានអនុវត្ត ប៉ុន្តែដូចជាពុំសូវទទួលបានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរនៅឡើយ។

ដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ យើងខ្ញុំសូមបញ្ចេញមតិដូចតទៅៈ

- ស្នើសុំអំពាវនាវដល់អាជ្ញាធរខេត្ត មន្ទីរ អាជ្ញាធរក្រុង ការិយាល័យពាក់ព័ន្ធមេត្តាបង្កើនការយកទុកដាក់ចុះណែនាំដល់ប្រជាពលរដ្ឋអំពីកិច្ចការងារមួយចំនួន ដែលប្រជាពលរដ្ឋគ្រប់រូបគប្បីធ្វើ ជាពិសេសការចូលរួមថែរក្សាការពារបរិស្ថាន និងបំផុសស្មារតីឱ្យមានការចូលរួមក្នុងការរៀបចំក្រុងមួយនេះឱ្យមានសោភ័ណភាព និងសណ្តាប់ធ្នាប់
- ស្នើសុំក្រសួង ស្ថាប័នពាក់ព័ន្ធ (អាជ្ញាធរថ្នាក់ជាតិ) សូមបន្ថែមកញ្ចប់ថវិកាលើផ្នែកអភិវឌ្ឍនគរូបនីយកម្មដល់អាជ្ញាធរខេត្ត ក្រុងឱ្យបានគ្រប់គ្រាន់ និងបន្ថែមមន្ត្រីជំនាញ ដើម្បីរៀបចំប្លង់គោលក្នុងការអភិវឌ្ឍក្រុងទៅថ្ងៃអនាគត
- បន្តរៀបចំភ្លើងលម្អតាមទីសាធារណៈ និងលើកទឹកចិត្តដល់ស្ថាប័នរដ្ឋ និងគ្រឹះស្ថានឯកជនឱ្យមានការរៀបចំតុបតែងភ្លើងនៅតាមអគាររបស់ខ្លួន
- បង្កើនការកសាង និងជួសជុលនូវហេដ្ឋារចនាសម្ព័ន្ធបន្ថែមទៀត ដូចជា ផ្លូវ សួនច្បារ ស្ពាន លំនៅដ្ឋាន មន្ទីរពេទ្យ។ល។

# ឯកសារយោង

## ច្បាប់

- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់, គ្មានលេខ, ២៤ ឧសភា ១៩៩៤។
- ច្បាប់ស្តីពីផ្លូវថ្នល់, លេខនស/រកម/០៥១៤/០០៨, ០៤ ឧសភា ២០១៤។
- ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក, លេខនស/រកម/០១១៥/០០១, ០៦ មករា ២០១៥។

## អនុក្រឹត្យ

- អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង, លេខ៤២អនក្រ.បក, ១០ កក្កដា ២០០០។
- អនុក្រឹត្យស្តីពីការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន, លេខ៤៧អនក្រ.បក, ១៧ មីនា ២០០៥។
- អនុក្រឹត្យស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក, លេខ២១៦អនក្រ.បក, ១៤ ធ្នូ ២០០៩។
- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម, លេខ១៣១អនក្រ.បក, ១៩ មីនា ២០១៤។
- អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ១១៣អនក្រ.បក, ២៧ សីហា ២០១៥។
- អនុក្រឹត្យស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក, លេខ១៦៨អនក្រ.បក, ១០ តុលា ២០១៧។
- អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់, លេខ២៣៥អនក្រ.បក, ២៥ ធ្នូ ២០១៧។

## ប្រកាស

- ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់សាខាកាំកុងត្រូលរាជធានី-ខេត្ត, លេខ ២៣៣៣.ណាបល.ប្រក, ១៤ កក្កដា ២០១៦។
- ប្រកាសស្តីពីការគ្រប់គ្រងសំណល់អាគុយ និងសំណង់ថ្មពិល, លេខ៤៤៧ប្រ.កប.ស្ថ., ២៧ តុលា ២០១៦។
- ប្រកាសស្តីពីនីតិវិធីនៃការត្រួតពិនិត្យ និងការធ្វើអធិការកិច្ចការបំពុលបរិស្ថាន, លេខ០១៩ប.ស្ថ., ១០ មករា ២០១៧។
- ប្រកាសស្តីពីការដាក់ឱ្យប្រើប្រាស់នូវកម្រិតកំណត់ស្តង់ដារបរិមាណជាតិពុល ឬសារធាតុគ្រោះថ្នាក់ដែលអនុញ្ញាតឱ្យបោះបង់ចោល, លេខ៣៨៧ប្រ.កប.ស្ថ., ១០ មករា ២០១៧។
- ប្រកាសស្តីពីការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំបច្ចេកទេសការត្រួតពិនិត្យការរំខានដោយសំឡេង និងរំញ័រពីការបំផ្ទុះ, លេខ០៥៧ប្រ.កប.ស្ថ., ១២ កុម្ភៈ ២០១៨។

**សារាចរ**

- សារាចរស្តីពីវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាព «ក្មេងទំនើង», លេខ០៤សរ, ២៤ មិថុនា ២០០៩។
- សារាចរអន្តរក្រសួងស្តីពីការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន, លេខ១០៧០ស.ជ.ណ.ប.ស្ត., ១២ វិច្ឆិកា ២០១៥។

**សេចក្តីណែនាំ/ផែនការណែនាំ/ផែនការសកម្មភាព**

- ផែនការណែនាំបន្ថែមអំពីការចាត់តាំងចលនាការពារសន្តិសុខមាតុភូមិ «ចលនាប្រជាការពារ», លេខ០៣៨ផក, ០៣ វិច្ឆិកា ២០០៥។
- ផែនការណែនាំស្តីពីការអនុវត្តប្រៀបសមរភូមិ ប្រឆាំងបទល្មើសគ្រឿងញៀន, លេខ០៥២ផក, ២១ សីហា ២០០៦។
- សេចក្តីណែនាំអនុវត្តសារាចររបស់រាជរដ្ឋាភិបាលស្តីពីវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាព «ក្មេងទំនើង», ០៧ កក្កដា ២០០៩។
- ផែនការសកម្មភាពស្តីពីការចាត់តាំងអនុវត្តវិធានការបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាព «ក្មេងទំនើង», លេខ០៥០ផក, ១៣ កក្កដា ២០០៩។
- ផែនការណែនាំស្តីពីការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ ឃុំមានសុវត្ថិភាព», លេខ០២២ផក, ១០ សីហា ២០១២។
- សេចក្តីណែនាំស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង-រាវ នៅក្នុងខេត្តកំពង់ស្ពឺ, លេខ១៣សណន, ០៤ ធ្នូ ២០១៥។
- សេចក្តីណែនាំស្តីពីការចូលរួមប្រារព្ធទិវាអនាម័យបរិស្ថានជាតិ ២៣ វិច្ឆិកា, លេខ០៥/១៧សណន, ១៥ វិច្ឆិកា ២០១៧។
- សេចក្តីណែនាំស្តីពីការអនុវត្តសាកល្បងប្រព័ន្ធទិន្នន័យសារធាតុបំពុលដែលសាយភាយ និងបំលាស់ទីចូលទៅក្នុងបរិស្ថាន, លេខ០០៦សណនប.ស្ត., ២៦ មេសា ២០១៨។

**សេចក្តីជូនដំណឹង**

- សេចក្តីជូនដំណឹងស្តីពីការបញ្ឈប់ការធ្វើចរាចរណ៍រថយន្តដឹកទំនិញធន់ធ្ងន់ រថយន្តប្រភេទបែនដឹកដី ថ្ម ខ្សាច់ ឆ្លងកាត់ផ្លូវជុំវិញបរិវេណសាលាខេត្តកំពង់ស្ពឺ, លេខ២៥៥សជណ, ២១ តុលា ២០១៦។
- សេចក្តីជូនដំណឹងស្តីពីការបញ្ឈប់ការលក់ដូរអនាធិបតេយ្យតាមចិញ្ចើមផ្លូវ និងរបងជុំវិញបរិវេណមណ្ឌលកីឡដ្ឋានខេត្តកំពង់ស្ពឺ, លេខ៥៣/១៧សជណ, ២៧ មីនា ២០១៧។
- សេចក្តីជូនដំណឹងស្តីពីការបញ្ឈប់ការលក់ដូរអនាធិបតេយ្យតាមចិញ្ចើមផ្លូវជុំវិញរបងសាលាខេត្ត ជុំវិញបរិវេណវិមានឯករាជ្យ និងជុំវិញសួនច្បារខាងលិច និងខាងកើត, លេខ២១៣/១៧សជណ, ១៩ តុលា ២០១៧។
- សេចក្តីជូនដំណឹងស្តីពីការដាក់ឱ្យដំណើរការភ្លើងស្តុបចរាចរណ៍ នៅក្នុងក្រុងច្បារមន, លេខ០២២/១៨សជណ, ០៩ កុម្ភៈ ២០១៨។

## សៀវភៅ

- គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត. *ស្តង់ដារទីក្រុងស្អាត*។
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ. ២០១១. *សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលក្រុង*. ក្រសួងមហាផ្ទៃ។
- បណ្ឌិត អ៊ុន សកក្កដា. ២០១៨. *នីតិនគរូបនីយវិទ្យា*។
- សាលាក្រុងច្បារមន. ២០១៥. *ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ (២០១៥-២០១៩) ក្រុងច្បារមន ខេត្តកំពង់ស្ពឺ*។
- សាលាក្រុងច្បារមន. ២០១៧. *កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៨-២០២០ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ*។

## របាយការណ៍

- សាលាក្រុងច្បារមន. ២០១៧. *របាយការណ៍ត្រីមាសទី១ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលក្រុងច្បារមន*. លេខ០៤/១៨រ.ប.ក. កំពង់ស្ពឺ៖ ច្បារមន, ០៨.សីហា។

## គេហទំព័រ

- គណនី Facebook របស់រដ្ឋបាលខេត្តកំពង់ស្ពឺ www.facebook.com/រដ្ឋបាលខេត្តកំពង់ស្ពឺ។
- គេហទំព័រសុខភាពកម្ពុជា www.healthcambodia.com។

# ឧបសម្ព័ន្ធរូបភាព

## មាតិកាឧបសម្ព័ន្ធរូបភាព

១.ផែនទីរដ្ឋបាលក្រុងច្បារមន និងសង្កាត់ទាំង ៥

២.ទិដ្ឋភាពទូទៅនៃការរៀបចំក្រុងច្បារមនឱ្យមានសោភ័ណភាព និងសណ្ដាប់ធ្នាប់

៣.គម្រោងអភិវឌ្ឍន៍មួយចំនួននៃក្រុងច្បារមននាពេលអនាគត។

# ផែនទីរដ្ឋបាលក្រុងច្បារមន និងសង្កាត់ទាំង ៥



# ផែនទីរដ្ឋបាលសង្កាត់ស្វាយក្រវ៉ាន់
# Svay Krovan Administration Map (050205)



# ផែនទីរដ្ឋបាលសង្កាត់សុព័រទេព
## Soportep Administration Map (050204)




| ល.រ | ភូមិ | កូដភូមិ | ផ្ទៃក្រឡាហិកតា |
|---|---|---|---|
| ១ | កាំងខ្នុ | [illegible] | 93.25 |
| ២ | រំលាង | [illegible] | 27.41 |
| ៣ | ថ្នល់ឈើទាល | [illegible] | 111.06 |
| ៤ | ត្រាចជុំ | [illegible] | 103.50 |
| ៥ | ប៊ែលប៉ៃហាល | [illegible] | 255.65 |
| ៦ | ក្រាំងផ្កា | [illegible] | 56.66 |
| ៧ | រំលាងប្រឡះ | [illegible] | 98.51 |
| ៨ | ព្រៃកន្ទាច | [illegible] | 72.52 |
| ៩ | ស្នាមទិព | [illegible] | 11.88 |
| ១០ | អាហ៊ំសង្ឃ | [illegible] | 109.91 |
| | ផ្ទៃដីសរុប | | 940.35 |

# ផែនទីរដ្ឋបាលសង្កាត់ច្បារមន
## Chbar Mon Commune Administration Map (050201)




| តំណាងសំគាល់ | | Legend |
|---|---|---|
| ▲ | ភូមិ | Village |
| ● | សង្កាត់ | Commune |
| ■ | មណ្ឌលសុខភាព | Health Center |
| — | ផ្លូវទឹក | Stream |
| — | ផ្លូវ | Road |
| — | ផ្លូវជាតិលេខ៤ | National Road 4 |
| - - - | ព្រំប្រទល់ភូមិ | Village Boundary |
| -·-·- | ព្រំប្រទល់សង្កាត់ | Commune Boundary |

**សង្កាត់ច្បារមន**

| ល.រ | ភូមិ | កូដភូមិ | ផ្ទៃក្រឡា(ហិកតា) |
|---|---|---|---|
| ១ | តាប៉ុល | 5020101 | 572.82 |
| ២ | ថ្នល់ | 5020102 | 313.31 |
| ៣ | ត្រពាំងលើក | 5020103 | 359.39 |
| ៤ | ពោធិ៍សង្ហារ | 5020104 | 108.31 |
| ៥ | [illegible] | 5020105 | 87.06 |
| ៦ | [illegible] | 5020106 | 248.67 |
| ៧ | ទួលក្រាំង | 5020107 | 84.57 |
| ៨ | [illegible] | 5020108 | 180.86 |
| ៩ | [illegible] | 5020109 | 79.49 |
| ១០ | សំបូរ | 5020110 | 121.00 |
| ១១ | [illegible] | 5020111 | 62.42 |
| ១២ | ព្រៃស្អិត | 5020112 | 38.28 |
| ១៣ | សំពៅ | 5020113 | 804.07 |
| | ផ្ទៃដីសរុប | | 3060.23 |



# ផែនទីរដ្ឋបាលសង្កាត់រកាធំ
# Roka Thom Administration Map 050203




## Legend

| | | |
|---|---|---|
| ▲ | ភូមិ | Village |
| ● | សង្កាត់ | Commune |
| ● | ក្រុង | District |
| H | មណ្ឌលសុខភាព | Health Center |
| — | ផ្លូវ | Road |
| — | ផ្លូវជាតិលេខ៤ | National Road 4 |
| — | ផ្លូវទឹក | Stream |
| ----- | ព្រំប្រទល់ភូមិ | Village boundary |
| ······ | ព្រំប្រទល់សង្កាត់ | Commume boundary |
| -·-·- | ព្រំប្រទល់ក្រុង | District boundary |

**សង្កាត់រកាធំ**

| ល.រ | ភូមិ | កូដភូមិ | ផ្ទៃក្រឡាហិកតា |
|---|---|---|---|
| ១ | ក្រាំងពលទេព | 5020301 | 115.16 |
| ២ | ពាណិជ្ជកម្ម | 5020302 | 59.52 |
| ៣ | បុរីក្សត្រ | 5020303 | 24.30 |
| ៤ | សំណាង | 5020304 | 54.12 |
| ៥ | មុខខេត្ត | 5020305 | 10.99 |
| ៦ | ស្មោទី១ | 5020306 | 133.21 |
| ៧ | អង្គរសី | 5020307 | 87.02 |
| ៨ | ថ្មី | 5020308 | 131.03 |
| ៩ | ទួលធ្នង់ | 5020309 | 233.76 |
| ១០ | ដោប | 5020310 | 203.75 |
| ១១ | រកាធំ | 5020311 | 109.72 |
| ១២ | ក្រាំងរលើក | 5020312 | 203.22 |
| | ផ្ទៃដីសរុប | | 1365.80 |



# ផែនទីរដ្ឋបាលសង្កាត់កណ្ដាលដុំ
# Kondol Dom Commune Administration Map (050202)




**សញ្ញាសំគាល់ Legend**

- ▲ ភូមិ Village
- ● សង្កាត់ Communce
- ● ក្រុង District
- ⊞ មណ្ឌលសុខភាព Health Center
- ផ្លូវ Road
- ផ្លូវជាតិលេខ៤ National Road 4
- ផ្លូវទឹក Stream
- ព្រំប្រទល់ភូមិ Village boundary
- ព្រំប្រទល់សង្កាត់ Commume boundary
- ព្រំប្រទល់ក្រុង District boundary

**សង្កាត់កណ្ដាលដុំ**

| ល.រ | ភូមិ | កូដភូមិ | ផ្ទៃក្រឡាហិកតា |
|---|---|---|---|
| ១ | ថ្មី | 5020201 | 371.98 |
| ២ | ពោះទៀង | 5020202 | 241.74 |
| ៣ | វាលរង | 5020203 | 119.51 |
| ៤ | ពង្រ | 5020204 | 148.50 |
| ៥ | ផ្សារសាមគ្គី | 5020205 | 23.47 |
| ៦ | ព្រៃ | 5020206 | 67.93 |
| ៧ | កណ្ដាលដុំ | 5020207 | 104.33 |
| ៨ | ត្រពាំងព្រះ | 5020208 | 157.55 |
| ៩ | កាប់ទូក | 5020209 | 62.37 |
| ១០ | ស្រែថ្នប់ | 5020210 | 66.56 |
| | ផ្ទៃដីសរុប | | 1363.94 |



# ទិដ្ឋភាពទូទៅនៃការរៀបចំក្រុងច្បារមនឱ្យមានសោភ័ណភាព និងសណ្តាប់ធ្នាប់







ប្លង់កាត់ទទឹងផ្លូវ
6,000
3,500
3,500
3,500
3,500
3,500
3,000
3,500
3,500
3,500
3,500
3,500
6,000
6,000
17,500
3,000
17,500
6,000
25,000
25,000
50,000






CAMBODIA


TOYOTA CAMRY








550
550
2270
980
1400
2000
2500
15950
19000
2600
6800
3100
1100
700
700
100
2500
1400
2500
300
1200
300
1000
400
2600
7000
2600
400
1000
300
300
1200
18600












ក្រុងច្បារមន
ទីក្រុងស្អាត
Clean City
ជ័យលាភីទីក្រុងស្អាត
២០១៥ - ២០១៨
CLEAN CITY AWARD
2015 - 2018


metfone
FREE
ALL






ផ្សាររាត្រីកំពង់ស្ពឺ
KAMPONG SPEU NIGHT MARKET
WELCOME
BEE MART


កម្សាន្ត សប្បាយ


បន្ទប់ទឹកសាធារណៈ










POLICE


POLICE
ARMANI










រូបភាព ស៊ីរីសុខុម






រូបភាព សិរីសុខុម



# គម្រោងអភិវឌ្ឍន៍មួយចំនួននៃក្រុងច្បារមនពេលអនាគត






bustransit



ទីតាំងទី ១

នៅទល់មុខផ្សារកំពង់ស្ពឺ

ជាទីប្រជុំជន និងជាចំណតរថយន្តដឹកអ្នកដំណើរទៅមក

ជាពិសេសរាល់ថ្ងៃៗ





ទីតាំងទី ៦

នៅទល់មុខរោងចក្រកាត់ដេរ Sabrina Gaarment Factory










សូមស្វាគមន៍
ក្រុងច្បារមន
Welcome to Chbamon City







# ឧបសម្ព័ន្ធគតិយុត្ត

# មាតិកាឧបសម្ព័ន្ធគតិយុត្ត

១.សេចក្តីណែនាំស្តីពីការគ្រប់គ្រងសំរាម សំណល់រឹង-រាវ នៅក្នុងខេត្តកំពង់ស្ពឺ

២.សេចក្តីជូនដំណឹងស្តីពីការបញ្ឈប់ការធ្វើចរាចរណ៍រថយន្តដឹកទំនិញធន់ធ្ងន់ រថយន្តប្រភេទបែន ដឹកដី ថ្ម ខ្សាច់ ឆ្លងកាត់ផ្លូវជុំវិញបរិវេណសាលាខេត្តកំពង់ស្ពឺ

៣.សេចក្តីជូនដំណឹងស្តីពីការបញ្ឈប់ការលក់ដូរអណាធិបតេយ្យតាមចិញ្ចើមផ្លូវ និងរបងជុំវិញ បរិវេណមណ្ឌលកីឡដ្ឋានខេត្តកំពង់ស្ពឺ

៤.សេចក្តីជូនដំណឹងស្តីពីការបញ្ឈប់ការលក់ដូរអណាធិបតេយ្យ តាមចិញ្ចើមផ្លូវជុំវិញរបងសាលា ខេត្ត ជុំវិញបរិវេណវិមានឯករាជ្យ និងជុំវិញសួនច្បារខាងលិច និងខាងកើត

៥.សេចក្តីណែនាំស្តីពីការចូលរួមប្រារព្ធទិវាអនាម័យបរិស្ថានជាតិ ២៣ វិច្ឆិកា

៦.សេចក្តីជូនដំណឹងស្តីពីការដាក់ឱ្យដំណើរការភ្លើងស្តុបចរាចរណ៍ នៅក្នុងក្រុងច្បារមន

៧.ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ (២០១៥-២០១៩) ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

៨.កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០១៨-២០២០ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ។